# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# ក្របខណ្ឌកម្មវិធីសិក្សា
# ចំណេះទូទៅនិងអប់រំបច្ចេកទេស




នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា

២០១៥

# មុខកថា

ជាងពីរទសវត្សរ៍កន្លងទៅនេះ សាកលភាវូបនីយកម្មលើគ្រប់វិស័យជាពិសេស វិស័យសេដ្ឋកិច្ច វិទ្យាសាស្ត្រ បច្ចេកទេស និងនយោបាយបានធ្វើឱ្យពិភពលោកកាន់តែមានការប្រកួតប្រជែងគ្នាផង និងសហការគ្នាផង ដើម្បីឈានទៅសម្រេចគោលដៅអភិវឌ្ឍសហស្សវត្សរ៍ និងការអភិវឌ្ឍប្រកបដោយចីរភាព។

កំណែទម្រង់ស៊ីជម្រៅក្នុងវិស័យអប់រំ ដើម្បីអភិវឌ្ឍធនធានមនុស្សប្រកបដោយវិជ្ជាសម្បទា បំណិនសម្បទា ចរិយាសម្បទា និងកាយសម្បទា ជាកត្តាកំណត់ជោគជ័យនៃការអភិវឌ្ឍលើវិស័យនានាទាំងអស់។

ប្រទេសកម្ពុជាបានឆ្លងកាត់ពីឋានៈនៃប្រទេសដែលមានចំណូលទាបទៅជាប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតទាបហើយកំពុងប្រែក្លាយខ្លួនឱ្យទៅជាប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០។ ដើម្បីសម្រេចបានចក្ខុវិស័យនេះ រាជរដ្ឋាភិបាលកម្ពុជាត្រូវធ្វើកំណែទម្រង់លើគ្រប់វិស័យជាពិសេសវិស័យអប់រំ សុខាភិបាល កសិកម្ម ឧស្សាហកម្ម និងទេសចរណ៍។ ក្រសួងអប់រំ យុវជន និងកីឡា បានដាក់ចេញនូវទិសដៅអាទិភាព១៥ ក្នុងរយៈពេលមធ្យមពីឆ្នាំ២០១៦-២០១៨ សម្រាប់កែទម្រង់វិស័យអប់រំរបស់ខ្លួន ជាពិសេសកំណែទម្រង់ការអប់រំគ្រូបង្រៀន និងក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅនិងអប់រំបច្ចេកទេស ដើម្បីធានាឱ្យកម្ពុជាមានធនធានមនុស្សដែលមានសមត្ថភាពសម្រាប់បម្រើដល់ការអភិវឌ្ឍលើគ្រប់វិស័យ។

ក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅ និងអប់រំបច្ចេកទេសនេះ ត្រូវបានរៀបចំឡើង ដើម្បីអប់រំពលរដ្ឋកម្ពុជាឱ្យទៅជាពលរដ្ឋពេញលេញ តាមរយៈការធ្វើឱ្យកម្មវិធីសិក្សាមានលក្ខណៈស្តង់ដាអន្តរជាតិទាំងខ្លឹមសារ វិធីសាស្ត្ររៀន និងបង្រៀន ព្រមទាំងវិធីវាយតម្លៃលទ្ធផលសិក្សារបស់សិស្ស ក្នុងគោលបំណងធ្វើឱ្យសមត្ថភាពសិស្សឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងារនៅកម្រិតជាតិ តំបន់ និងពិភពលោក។

ក្រសួងអប់រំ យុវជន និងកីឡា សង្ឃឹមថាអង្គភាពពាក់ព័ន្ធថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិទាំងអស់នឹងចូលរួមសហការនិងគាំទ្រក្នុងការអនុវត្តក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅនិងបច្ចេកទេសនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ដើម្បីជាប្រយោជន៍សម្រាប់អភិវឌ្ឍសមត្ថភាពពលរដ្ឋខ្មែរ។

ក្រសួងអប់រំ យុវជន និងកីឡា សូមថ្លែងអំណរគុណចំពោះគណៈកម្មការ អនុគណៈកម្មការ ក្រុមការងារបច្ចេកទេសចំពោះកិច្ច និងអ្នកពាក់ព័ន្ធផ្សេងទៀត ដែលបានយកចិត្តទុកដាក់ស្រាវជ្រាវនិងរៀបចំក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅនិងអប់រំបច្ចេកទេសនេះឡើង។

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ មករា ឆ្នាំ២០១៦

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

បណ្ឌិត ហង់ ជួន ណារ៉ុន

# អារម្ភកថា

យោងតាមលទ្ធផលនៃការសិក្សាស្រាវជ្រាវស្ដីពីប្រសិទ្ធភាពនិងលទ្ធផលនៃការប្រឡងមធ្យមសិក្សាទុតិយភូមិឆ្នាំ២០១៤ គុណភាពអប់រំចំណេះទូទៅនាពេលបច្ចុប្បន្ននៅមានកម្រិតនៅឡើយ។ សិស្សមួយចំនួនបានបោះបង់ការសិក្សានៅមុនពេលពួកគេចេះអាននិងសរសេរ។ អក្ខរកម្មវិជ្ជាជីវៈរបស់សិស្សនៅមានកម្រិត បើទោះបីជាពួកគេបានបញ្ចប់បឋមសិក្សាឬមធ្យមសិក្សាបឋមភូមិក៏ដោយ។ ចំនួនសិស្សមិនដល់ពាក់កណ្ដាលទេដែលបានប្រឡងជាប់មធ្យមសិក្សាទុតិយភូមិកាលពីឆ្នាំ២០១៤។

គុណភាពអប់រំបានទទួលរងឥទ្ធិពលពីកត្តាជាច្រើន ជាពិសេសកម្មវិធីសិក្សាដែលរួមបញ្ចូលទាំងឯកសារពាក់ព័ន្ធនឹងក្របខណ្ឌកម្មវិធីសិក្សាកម្មវិធីសិក្សាលម្អិត សៀវភៅគ្រូ សៀវភៅសិស្ស សៀវភៅសិក្សាអនុវត្តសម្ភារៈឧបទេស មន្ទីរពិសោធន៍វិទ្យាសាស្ត្រ និងសៀវភៅណែនាំអំពីការវាយតម្លៃសមត្ថភាពសិស្ស។ ឯកសារទាំងអស់នេះត្រូវតែរៀបចំឡើងដោយមានការសិក្សាស្រាវជ្រាវនិងពិគ្រោះយោបល់ឱ្យបានល្អិតល្អន់ទៅលើមុខវិជ្ជានិងមុខវិជ្ជារងនីមួយៗ និងរវាងកម្រិតថ្នាក់មួយទៅកម្រិតថ្នាក់មួយទៀត ដើម្បីធានានូវប្រសិទ្ធភាពនៃការរៀននិងការបង្រៀន និងការពាក់ព័ន្ធនៃចំណេះដឹងសម្រាប់បម្រើការរស់នៅប្រចាំថ្ងៃ។ ការរៀបចំបែបនេះនឹងធ្វើឱ្យទំនាក់ទំនងនៃខ្លឹមសារមេរៀននៃមុខវិជ្ជានីមួយៗ មានភាពប្រទាក់ក្រឡាគ្នានិងភាពរលូនទៅតាមការបែងចែកនៃការអភិវឌ្ឍកម្មវិធីសិក្សាតាមលក្ខណៈវិទ្យាសាស្ត្រ ដែលកំណត់ច្បាស់លាស់អំពីវិជ្ជាសម្បទា បំណិនសម្បទា ចរិយាសម្បទា និងកាយសម្បទាដែលសិស្សនឹងត្រូវទទួលបានក្រោយពេលរៀនមេរៀននីមួយៗ។

ក្របខណ្ឌកម្មវិធីសិក្សាត្រូវបានរៀបចំឡើងដើម្បីឱ្យឆ្លើយតបទៅនឹងស្ថានភាពអប់រំតាមបណ្ដាប្រទេសនៅក្នុងសហគមន៍អាស៊ាន ដែលធានាឱ្យអ្នកសិក្សាមានសមត្ថភាពឆ្លើយតបទៅនឹងតម្រូវការរបស់ខ្លួន តម្រូវការទីផ្សារការងារក្នុងប្រទេស ក្នុងតំបន់ និងសកលលោក។

ក្របខណ្ឌកម្មវិធីសិក្សាជាឯកសារគន្លឹះសម្រាប់អភិវឌ្ឍឯកសារសំខាន់ៗដោយអ្នកពាក់ព័ន្ធ ដូចជាសៀវភៅសិក្សា សម្ភារៈឧបទេសដែលបម្រើឱ្យការរៀននិងការបង្រៀន សេចក្ដីណែនាំស្ដីពីវិធីសាស្ត្របង្រៀន និងសូចនាករនៃលទ្ធផលសិក្សារំពឹងទុកសម្រាប់វាយតម្លៃសមត្ថភាពសិស្សទៅតាមកម្រិតថ្នាក់និងទៅតាមមុខវិជ្ជាដែលមានលក្ខណៈសត្យានុម័ត អាចប្រមើលមើលដឹងជាមុននិងមានតម្លាភាព។

ក្របខណ្ឌកម្មវិធីសិក្សាត្រូវបានរៀបចំឡើងដោយឈរលើមូលដ្ឋានទស្សនៈនិងចក្ខុវិស័យថ្មីស្របតាមនិន្នាការអប់រំសាកល រដ្ឋធម្មនុញ្ញ យុទ្ធសាស្ត្រចតុកោណដំណាក់កាលទីបី ច្បាប់អប់រំ ផែនការជាតិអប់រំសម្រាប់ទាំងអស់គ្នា ផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០១៤ដល់ឆ្នាំ២០១៨ និងកម្មវិធីសិក្សាពីឆ្នាំ១៩៨០ដល់ឆ្នាំ២០០៩។

គណៈកម្មការនិងអនុគណៈកម្មការអភិវឌ្ឍក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅ សូមថ្លែងអំណរគុណដល់ភាគីពាក់ព័ន្ធទាំងអស់ ជាពិសេស នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សាដែលបានផ្ដល់នូវឯកសារពាក់ព័ន្ធនិងពុទ្ធិជាច្រើនក្នុងការតាក់តែងកម្មវិធីសិក្សានេះឱ្យកាន់តែមានភាពល្អប្រសើរឡើង។

**គណៈកម្មការរៀបចំក្របខណ្ឌកម្មវិធីសិក្សា**

# គណៈកម្មការ

គណៈកម្មការគ្រប់គ្រង

១- ឯកឧត្តមបណ្ឌិត ហង់ ជួន ណារ៉ុន
២- ឯកឧត្តមបណ្ឌិត ណាត ប៊ុនរឿន
៣- ឯកឧត្តមបណ្ឌិត អ៊ឹម កុច
៤- លោកជំទាវ ទន់ សាអ៊ឹម
៥- ឯកឧត្តម ពុត សាមិត្ត
៦- លោក អោ សៀម

គណៈកម្មការចំពោះកិច្ចរៀបចំក្របខណ្ឌកម្មវិធីសិក្សា

១- ឯកឧត្តមបណ្ឌិត ជេត ជាលី
២- បណ្ឌិត ម៉ុក សារ៉ុម
៣- លោក អោ សៀម
៤- បណ្ឌិត ងិន ច័ន្ទរិទ្ធ
៥- បណ្ឌិត ឈិញ ស៊ីថា
៦- បណ្ឌិត ហ៊ាន សុខុម
៧- បណ្ឌិត ជ័យ ចាន់អឿន
៨- បណ្ឌិត ស៊ាម ង៉ុន

គណៈកម្មការពិនិត្យ

១- ឯកឧត្តមបណ្ឌិត ច័ន្ទ សំណព្វ
២- បណ្ឌិត ម៉ុក សារ៉ុម
៣- បណ្ឌិត ឈិញ ស៊ីថា
៤- បណ្ឌិត ជ័យ ចាន់អឿន

ជំនួយការបច្ចេកទេស

១- បណ្ឌិត កេង ច័ន្ទសុភ័ក្រ
២- លោក លី គិមឡុង
៣- វេជ្ជបណ្ឌិត ចុង វណ្ណដារ៉ា
៤- លោក ហោ យូហាន

# មាតិកា


**បុព្វកថា**........................................ I
**អារម្ភកថា**........................................ II
**គណៈកម្មការ**........................................ III
**មាតិកា**........................................ IV
**បញ្ជីតារាង**........................................ VI

**១- សេចក្តីផ្តើម**........................................ ១
**២- ចក្ខុវិស័យនៃក្របខណ្ឌកម្មវិធីសិក្សា**........................................ ៣
**៣- គោលបំណងក្របខណ្ឌកម្មវិធីសិក្សា**........................................ ៣
**៤- សមត្ថភាពសំខាន់ៗរបស់សិស្ស**........................................ ៤
៤.១- អក្ខរសាស្ត្រនិងលេខសាស្ត្រ........................................ ៤
៤.២- ភាសាបរទេស........................................ ៤
៤.៣- បច្ចេកវិទ្យាព័ត៌មាននិងទូរគមនាគមន៍ (ICT)........................................ ៤
៤.៤- ប្រាស្រ័យទាក់ទងនិងធ្វើការងារជាក្រុម........................................ ៤
៤.៥- ពិចារណានិងការបង្កើតថ្មី........................................ ៥
៤.៦- អនុវត្តចំណេះដឹងនិងជំនាញ........................................ ៥
៤.៧- អភិវឌ្ឍបុគ្គលគ្រួសារនិងសង្គម........................................ ៥
៤.៨- សហគ្រិនភាពនិងភាពជាអ្នកដឹកនាំ........................................ ៥
**៥- គោលបំណងតាមមុខវិជ្ជានិងមុខវិជ្ជារង**........................................ ៥
៥.១- ភាសាខ្មែរនិងអក្សរសាស្ត្រខ្មែរ........................................ ៥
៥.២- គណិតវិទ្យា........................................ ៦
៥.៣- សិក្សាសង្គម........................................ ៧
៥.៤- វិទ្យាសាស្ត្រ........................................ ៧
៥.៥- បច្ចេកវិទ្យាព័ត៌មាននិងទូរគមនាគមន៍(ICT)........................................ ៨
៥.៦- ភាសាបរទេស(អង់គ្លេសនិង/ឬបារាំង)........................................ ៨
៥.៧- អប់រំកាយនិងកីឡា........................................ ៩
៥.៨- អប់រំសុខភាព........................................ ១០
៥.៩- អប់រំសិល្បៈ........................................ ១០
៥.១០- បំណិនជីវិតតាមមូលដ្ឋាន........................................ ១១

**៦-** **មុខវិជ្ជាសិក្សានិងម៉ោងសិក្សាតាមភូមិសិក្សា**........ ១១
៦.១- មត្តេយ្យសិក្សា........ ១១
៦.២- បឋមសិក្សា........ ១២
៦.៣- មធ្យមសិក្សាបឋមភូមិ........ ១៤
៦.៤- មធ្យមសិក្សាទុតិយភូមិ........ ១៦
៦.៥- អប់រំបច្ចេកទេស........ ១៨
**៧-** **គោលការណ៍នៃការបង្រៀន**........ ២០
៧.១- គោលការណ៍ទី១........ ២០
៧.២- គោលការណ៍ទី២........ ២០
៧.៣- គោលការណ៍ទី៣........ ២០
៧.៤- គោលការណ៍ទី៤........ ២០
**៨-** **វាយតម្លៃការរៀននិងបង្រៀន**........ ២០
៨.១- គោលការណ៍ទី១ : វាយតម្លៃសមត្ថភាពរបស់សិស្សនិងគ្រូបង្រៀន........ ២០
៨.២- គោលការណ៍ទី២ : វាយតម្លៃពីប្រសិទ្ធភាពនិងប្រសិទ្ធផលរបស់ប្រព័ន្ធអប់រំ........ ២០
៨.៣- គោលការណ៍ទី៣ : ស្ថាប័នមានសមត្ថកិច្ចវាយតម្លៃអប់រំ........ ២០
៨.៤- គោលការណ៍ទី៤ : ក្របខណ្ឌវាយតម្លៃអប់រំ........ ២១
៨.៥- គោលការណ៍ទី៥ : ការប្រើប្រាស់លទ្ធផលនៃការវាយតម្លៃ........ ២១
**៩-** **ការអភិវឌ្ឍសមត្ថភាពគ្រូបង្រៀន**........ ២២
**១០-** **ការអនុវត្តក្របខណ្ឌកម្មវិធីសិក្សា**........ ២២

**ឯកសារពិគ្រោះ**........ ២៣

**ឧបសម្ព័ន្ធ១ ៖ សន្ទានុក្រម**........ ២៦
**ឧបសម្ព័ន្ធ២ ៖ សមត្ថភាពរំពឹងទុកតាមភូមិសិក្សា**........ ២៨
**ឧបសម្ព័ន្ធ៣ ៖ សីមាអភិវឌ្ឍពលរដ្ឋពេញលេញ**........ ៣១

# បញ្ជីតារាង

**តារាង១ :** របាយមុខវិជ្ជានិងម៉ោងសិក្សាសម្រាប់មត្តេយ្យសិក្សា........................................................ ១២
**តារាង២ :** របាយមុខវិជ្ជានិងម៉ោងសិក្សាពីថ្នាក់ទី១ដល់ថ្នាក់ទី៦........................................................ ១៣-១៤
**តារាង៣ :** របាយមុខវិជ្ជានិងម៉ោងសិក្សាពីថ្នាក់ទី៧ដល់ថ្នាក់ទី៩........................................................ ១៥
**តារាង៤ :** របាយមុខវិជ្ជានិងម៉ោងសិក្សាថ្នាក់ទី១០ ទី១១ និងទី១២ បណ្តុំវិទ្យាសាស្ត្រ.................... ១៧
**តារាង៥ :** របាយមុខវិជ្ជានិងម៉ោងសិក្សាថ្នាក់ទី១០ ទី១១ និងទី១២ បណ្តុំវិទ្យាសាស្ត្រសង្គម........... ១៨
**តារាង៦ :** របាយមុខវិជ្ជានិងម៉ោងសិក្សាឆ្នាំទី១ ឆ្នាំទី២ និងឆ្នាំទី៣.................................................... ១៩

## ១-	សេចក្តីផ្តើម

**ចាប់តាំងពីឆ្នាំ១៩៧៩ ដល់បច្ចុប្បន្ននេះ ការអភិវឌ្ឍកម្មវិធីសិក្សា មានការផ្លាស់ប្តូរជាបួនដំណាក់កាល។**

នៅដំណាក់កាលទី១ ពីឆ្នាំ១៩៨០ដល់ឆ្នាំ១៩៨៧ នាសម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា កម្មវិធីសិក្សាមានបីកម្រិត៖ កម្មវិធីបឋមសិក្សាវិជ្ជាទូទៅ (កម្រិតសិក្សាទី១) កម្មវិធីកម្រិតសិក្សាទី២ និង កម្មវិធីកម្រិតសិក្សាទី៣។

នៅដំណាក់កាលទី២ ពីឆ្នាំ១៩៨៧ដល់ឆ្នាំ១៩៩៦ នាសម័យរដ្ឋកម្ពុជា កម្មវិធីសិក្សាត្រូវបាន បែងចែកជាកម្មវិធីបឋមសិក្សាចំណេះទូទៅ (កម្រិតសិក្សាទី១) កម្មវិធីកម្រិតសិក្សាទី២ និងកម្មវិធីកម្រិត សិក្សាទី៣។

នៅដំណាក់កាលទី៣ ពីឆ្នាំ១៩៩៦ដល់ឆ្នាំ២០០៥ នាសម័យព្រះរាជាណាចក្រកម្ពុជា កម្មវិធី សិក្សារួមមាន កម្មវិធីសិក្សាគោលសម្រាប់បឋមសិក្សា កម្មវិធីសិក្សាគោលសម្រាប់មធ្យមសិក្សាបឋមភូមិ និងកម្មវិធីសិក្សាគោលសម្រាប់មធ្យមសិក្សាទុតិយភូមិ។

នៅដំណាក់កាលទី៤ ពីឆ្នាំ២០០៥ដល់ឆ្នាំ២០០៩ នាសម័យព្រះរាជាណាចក្រកម្ពុជាទី២ ក្រសួង អប់រំ យុវជន និងកីឡាបានអភិវឌ្ឍគោលនយោបាយសម្រាប់អភិវឌ្ឍកម្មវិធីសិក្សាចំណេះទូទៅ កម្មវិធីសិក្សា គោលសម្រាប់អប់រំមូលដ្ឋានចំណេះទូទៅ (ពីថ្នាក់ទី១ដល់ទី៩) និងកម្មវិធីសិក្សាគោលសម្រាប់មធ្យមសិក្សា ទុតិយភូមិ (ពីថ្នាក់ទី១០ដល់ទី១២)។

លទ្ធផលនៃការសិក្សាទៅលើកម្មវិធីសិក្សានិងការវិភាគសៀវភៅសិក្សាគោលដែលកំពុងប្រើប្រាស់ នាពេលបច្ចុប្បន្នបានបង្ហាញពីភាពចាំបាច់ដើម្បីធានាថាខ្លឹមសារមេរៀននៅក្នុងសៀវភៅសិក្សាគោលមាន ការពាក់ព័ន្ធគ្នាពីមុខវិជ្ជាមួយទៅមុខវិជ្ជាមួយតាមលំដាប់លំដោយនិងគ្រប់ជ្រុងជ្រោយ។លើសពីនេះទៅ ទៀត មេរៀនខ្លះនៃមុខវិជ្ជាមួយចំនួន ជាពិសេសមុខវិជ្ជាគណិតវិទ្យានិងវិទ្យាសាស្ត្រនៅក្នុងកម្មវិធីសិក្សា ចំណេះទូទៅត្រូវឱ្យមានការពាក់ព័ន្ធទៅនឹងការអនុវត្តជាក់ស្តែងនៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃនិងការវិវត្ត របស់ពិភពលោក។ សិស្សដែលបញ្ចប់ការសិក្សាពីភូមិសិក្សានីមួយៗមិនមានសមត្ថភាពគ្រប់គ្រាន់សម្រាប់ ប្រកបកិច្ចការរស់នៅ សម្រាប់បន្តការសិក្សានៅសាលាបច្ចេកទេសឬនៅគ្រឹះស្ថានឧត្តមសិក្សា។

ដូច្នេះ ការអភិវឌ្ឍកម្មវិធីសិក្សានៅដំណាក់កាលទី៥នេះ គឺដើម្បីធ្វើឱ្យសមត្ថភាពសិស្សដែលបញ្ចប់ ការសិក្សាពីភូមិសិក្សានីមួយៗមានចំណេះដឹង បំណិន និងឥរិយាបថ សម្រាប់ប្រកបកិច្ចការរស់នៅប្រចាំថ្ងៃ និងសម្រាប់បន្តការសិក្សា។ ជាងនេះទៅទៀតក្របខណ្ឌកម្មវិធីសិក្សានេះ គឺធ្វើឱ្យកាន់តែប្រសើរឡើងនូវ គុណភាពអប់រំដែលឆ្លើយតបទៅនឹងការប្រែប្រួលរបស់ពិភពលោកនិងឆ្លើយតបទៅនឹងយុទ្ធសាស្ត្រ ចតុកោណរបស់រាជរដ្ឋាភិបាលដំណាក់កាលទី៣ដែលបានបង្ហាញពីការប្តេជ្ញាចិត្តរបស់កម្ពុជាក្នុងការប្រែ ក្លាយទៅជាប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់ត្រឹមឆ្នាំ២០៣០និងជាប្រទេសមានប្រាក់ចំណូល ខ្ពស់នៅឆ្នាំ២០៥០។ ដើម្បីសម្រេចបាននូវគោលដៅនេះ ប្រទេសកម្ពុជាត្រូវការលើកកម្ពស់កត្តា សំខាន់ៗ ដែលជួយទ្រទ្រង់កំណើនសេដ្ឋកិច្ចរបស់ខ្លួននិងបង្កើនការប្រកួតប្រជែង ខណៈដែលប្រទេស កម្ពុជាកំពុងពង្រីកខ្លួនចូលទៅក្នុងឧស្សាហកម្មថ្មីនៃទីផ្សារការងារថ្នាក់ជាតិ តំបន់ និងអន្តរជាតិ។

ដើម្បីឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងារ សមាហរណកម្មអាស៊ាន និងការប្រែប្រួលរបស់ពិភពលោក ការអភិវឌ្ឍក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅថ្មីឱ្យមានលក្ខណៈទាន់សម័យនិងវិទ្យាសាស្ត្រសម្រាប់បង្កើតពលរដ្ឋពេញលេញ ជាកត្តាអាទិភាពនិងចាំបាច់ជាទីបំផុត។

ក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅនេះ ត្រូវបានអភិវឌ្ឍឡើងដោយផ្អែកទៅលើគោលនយោបាយសម្រាប់អភិវឌ្ឍកម្មវិធីសិក្សាឆ្នាំ២០០៥ដល់ឆ្នាំ២០០៩ ក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅនៃបណ្តាប្រទេសក្នុងសហគមអាស៊ានមួយចំនួនដូចជាប្រទេសសិង្ហបុរី ប្រទេសម៉ាឡេស៊ី ប្រទេសថៃ និងរបាយការណ៍ទស្សនកិច្ចសិក្សានៅប្រទេសសិង្ហបុរី។

ចំណុចសំខាន់ៗដែលត្រូវបានកែសម្រួលនិងបន្ថែមពីលើគោលនយោបាយអភិវឌ្ឍកម្មវិធីសិក្សាឆ្នាំ២០០៥ដល់ឆ្នាំ២០០៩ ដែលមានដូចខាងក្រោមត្រូវបានធ្វើឡើងដើម្បីឆ្លើយតបទៅនឹងអនុសាសន៍ដែលត្រូវបានលើកឡើងនៅក្នុងការសិក្សាស្រាវជ្រាវនានាស្តីអំពីលទ្ធផលសិក្សារបស់សិស្ស ភាពប្រទាក់ក្រឡាគ្នានៃកម្មវិធីសិក្សាពីភូមិសិក្សាមួយទៅភូមិសិក្សាមួយទៀត ពីមុខវិជ្ជាមួយទៅមុខវិជ្ជាមួយទៀត និងភាពឆ្លើយតបនៃកម្មវិធីសិក្សាពីមធ្យមសិក្សាទៅឧត្តមសិក្សានិងទីផ្សារការងារ។

- កែសម្រួលក្របខណ្ឌកម្មវិធីសិក្សាពីមត្តេយ្យសិក្សារហូតដល់មធ្យមសិក្សាដើម្បីឱ្យមានសង្គតិភាពនិងភាពប្រទាក់ក្រឡាគ្នារវាងកម្រិតថ្នាក់និងមុខវិជ្ជា
- លទ្ធផលរំពឹងទុកតាមភូមិសិក្សាត្រូវបានរៀបចំឡើង
- បញ្ចូលការសិក្សាភាសាបរទេស (អង់គ្លេសឬបារាំង) ចាប់ពីថ្នាក់ទី១ដល់ថ្នាក់ទី៦ជាមុខវិជ្ជាគោលនៃកម្មវិធីសិក្សា
- បញ្ចូលមុខវិជ្ជាសិក្សាបច្ចេកវិទ្យាព័ត៌មាននិងទូរគមនាគមន៍ (ICT) ចាប់ពីថ្នាក់ទី៤ ដល់ថ្នាក់ទី១២ ទៅក្នុងកម្មវិធីសិក្សា
- បញ្ចូលបំណិនជីវិតតាមមូលដ្ឋានចាប់ពីថ្នាក់ទី៤ដល់ថ្នាក់ទី៩ ជាមុខវិជ្ជាគោលក្នុងកម្មវិធីសិក្សា (សាលាមានកាតព្វកិច្ចជ្រើសរើសមេរៀនបំណិនជីវិតឱ្យសមស្របតាមស្ថានភាពជាក់ស្តែង)
- បំបែកមុខវិជ្ជាអប់រំសុខភាព អប់រំសិល្បៈ និងអប់រំកាយនិងកីឡា
- បញ្ចូលគោលការណ៍ណែនាំស្តីអំពីទំនើបកម្មវិធីសាស្ត្របង្រៀននៅគ្រប់កម្រិតសិក្សា
- បញ្ចូលគោលការណ៍ណែនាំស្តីអំពីការអភិវឌ្ឍសមត្ថភាពគ្រូបង្រៀនលើកម្មវិធីសិក្សាថ្មីនិងការវាយតម្លៃការរៀននិងបង្រៀន
- រៀបចំទម្រង់នៃប្រព័ន្ធអប់រំថ្មីតាមរចនាសម្ព័ន្ធដែលសិស្សនៅមធ្យមសិក្សាទុតិយភូមិចាប់ពីថ្នាក់ទី១០ទៅ មានជម្រើសបីសម្រាប់ជ្រើសរើស រួមមានវិទ្យាសាស្ត្រពិត វិទ្យាសាស្ត្រសង្គម អប់រំបច្ចេកទេសនិងបណ្តុះបណ្តាលវិជ្ជាជីវៈដោយអនុលោមទៅតាមក្របខណ្ឌគុណវុឌ្ឍជាតិ។
- បញ្ចូលក្របខណ្ឌកម្មវិធីសិក្សា ស្តង់ដា និងសូចនាករជាឯកសារតែមួយសម្រាប់ជំនួយដល់ការអភិវឌ្ឍសៀវភៅសិក្សាគោល សៀវភៅគ្រូ សៀវភៅអនុវត្ត និងសម្ភារៈឧបទេសនានាសម្រាប់បម្រើឱ្យការរៀននិងការបង្រៀនឱ្យកាន់តែសម្បូរបែបនិងមានបច្ចុប្បន្នភាព។

- បញ្ចូលការអប់រំបញ្ចូលគ្នានិងការអប់រំពិសេសដើម្បីលើកកម្ពស់ការអប់រំប្រកបដោយនិរន្តរភាព
- បញ្ចូលប្រព័ន្ធវាយតម្លៃថ្នាក់សាលារៀន ថ្នាក់ជាតិ ថ្នាក់តំបន់។

ក្នុងការអភិវឌ្ឍក្របខណ្ឌកម្មវិធីសិក្សានេះមានការពិគ្រោះយោបល់ជាច្រើនលើកតាមរូបភាពសិក្ខាសាលាពិគ្រោះយោបល់ផ្ទៃក្នុងនាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា មន្ទីរអប់រំ យុវជន និងកីឡា ២៥រាជធានី ខេត្ត និងជាមួយដៃគូអភិវឌ្ឍផ្នែកអប់រំ។

ក្រសួងអប់រំ យុវជន និងកីឡាបានចាប់ផ្តើមកំណែទម្រង់ប្រព័ន្ធអប់រំ ជាពិសេស ពិនិត្យនិងកែលម្អឡើងវិញនូវកម្មវិធីសិក្សាលើការរៀននិងការបង្រៀន រៀបចំក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅដើម្បីរួមចំណែកអភិវឌ្ឍធនធានមនុស្សឱ្យទទួលបាននូវចំណេះដឹង បំណិន សីលធម៌ល្អ បុគ្គលិកលក្ខណៈពេញលេញ និងមានលទ្ធភាពក្នុងការចូលរួមអភិវឌ្ឍប្រទេសជាតិប្រកបដោយគុណភាព។

## ២- ចក្ខុវិស័យនៃក្របខណ្ឌកម្មវិធីសិក្សា

ចក្ខុវិស័យរបស់ក្របខណ្ឌកម្មវិធីសិក្សានេះ ធានាអប់រំពលរដ្ឋឱ្យមានលក្ខណសម្បត្តិពេញលេញប្រកបដោយភាពរីកចម្រើនគ្រប់ផ្នែកដោយមានតុល្យភាពរវាងវិជ្ជាសម្បទា បំណិនសម្បទា ចរិយាសម្បទា កាយសម្បទានិងមនសិការស្នេហាជាតិនិងមនុស្សជាតិ ដើម្បីការអភិវឌ្ឍជាតិនិងការធ្វើសមាហរណកម្មកម្ពុជាទៅក្នុងតំបន់ និងពិភពលោក។

## ៣- គោលបំណងនៃក្របខណ្ឌកម្មវិធីសិក្សា

គោលបំណងនៃ "*ក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅនិងអប់រំបច្ចេកទេស*" នេះ ដើម្បីអភិវឌ្ឍ៖

៣.១- សមត្ថភាពភាសាខ្មែរនិងភាសាបរទេសលើបំណិនទាំងបួន (ការស្តាប់ ការនិយាយ ការអាន និងការសរសេរ) ឱ្យបានច្បាស់លាស់សម្រាប់ប្រើប្រាស់ក្នុងការសិក្សាស្រាវជ្រាវនិងការប្រាស្រ័យទាក់ទងក្នុងការរស់នៅប្រចាំថ្ងៃ។

៣.២- ចំណេះដឹងគណិតវិទ្យា វិទ្យាសាស្ត្រ បច្ចេកទេសនិងបច្ចេកវិទ្យាព័ត៌មាននិងទូរគមនាគមន៍សម្រាប់ជាមូលដ្ឋានដល់ការបន្តការសិក្សានិងការប្រាស្រ័យទាក់ទងក្នុងការរស់នៅប្រចាំថ្ងៃ។

៣.៣- បំណិនសិល្បៈ សុខភាព កីឡា សោភ័ណភាព នវានុវត្តន៍ សហគ្រិនភាព និងពលរដ្ឋវិជ្ជាសម្រាប់ការប្រើប្រាស់ប្រចាំថ្ងៃក្នុងនាមជាបុគ្គលនិងសមាជិកគ្រួសារ សហគមន៍ និងសង្គម។

៣.៤- បំណិនស្វ័យសិក្សា ស្រាវជ្រាវត្រិះរិះពិចារណា ប្រាស្រ័យទាក់ទង និងដោះស្រាយបញ្ហាក្នុងបរិបទផ្សេងៗ ដោយប្រើប្រាស់ចំណេះដឹងទូលំទូលាយនិងស៊ីជម្រៅ។

៣.៥- សមត្ថភាពក្នុងការវាយតម្លៃនិងធ្វើសេចក្តីសម្រេចចិត្តដោយសុភវិនិច្ឆ័យនិងការទទួលខុសត្រូវប្រកបដោយសេចក្តីថ្លៃថ្នូរ ចិត្តមេត្តាករុណានូវរាល់សកម្មភាពរបស់ខ្លួនក្នុងនាមជាបុគ្គលនិងសមាជិកគ្រួសារ សហគមន៍ និងសង្គម។

៣.៦- ការយល់ដឹងក្នុងការបំពេញកាតព្វកិច្ចនិងការប្រើប្រាស់សិទ្ធិពលរដ្ឋដោយមានការទទួលខុសត្រូវក្នុងនាមជាបុគ្គលនិងសមាជិកគ្រួសារ សហគមន៍ សង្គម តំបន់ និងពិភពលោក។

៣.៧- បំណិនសិក្សាពេញមួយជីវិតជួយលើកកម្ពស់គុណតម្លៃជាមូលដ្ឋាននិងបង្កើនចំណេះដឹងឱ្យទូលំទូលាយស្តីពីសេដ្ឋកិច្ច នយោបាយ ប្រវត្តិសាស្ត្រ វប្បធម៌ សាសនា ជាតិសាសន៍ អត្តសញ្ញាណជាតិ និងបរិស្ថានរបស់ប្រទេសខ្លួន ប្រទេសក្នុងតំបន់ និងពិភពលោក ដើម្បីលើកកម្ពស់ការអប់រំជាពលរដ្ឋសកម្ម និងពលរដ្ឋសាកលប្រកបដោយចីរភាពនិងសន្តិសហវិជ្ជមានជាមនុស្សជាតិ។

៣.៨- ស្មារតីស្រឡាញ់ ការពារ និងកសាងជាតិ មាតុភូមិ និងពូជសាសន៍របស់ខ្លួនដោយអនុវត្តគោលការណ៍ប្រជាធិបតេយ្យសេរីពហុបក្សនិងការគោរពសិទ្ធិមនុស្សដោយឈរលើច្បាប់ជាតិនិងអន្តរជាតិ។

## ៤- សមត្ថភាពសំខាន់ៗរបស់សិស្ស

៤.១- អក្ខរសាស្ត្រនិងលេខសាស្ត្រ

៤.២- ភាសាបរទេស

៤.៣- បច្ចេកវិទ្យាព័ត៌មាននិងទូរគមនាគមន៍ (ICT)

៤.៤- ប្រាស្រ័យទាក់ទងនិងធ្វើការងារជាក្រុម

៤.៥- ពិចារណានិងការបង្កើតថ្មី

៤.៦- អនុវត្តចំណេះដឹងនិងជំនាញ

៤.៧- អភិវឌ្ឍបុគ្គលគ្រួសារនិងសង្គម

៤.៨- សហគ្រិនភាពនិងភាពជាអ្នកដឹកនាំ

### ៤.១- អក្ខរសាស្ត្រនិងលេខសាស្ត្រ

អក្ខរសាស្ត្រនិងលេខសាស្ត្រ គឺជាសមត្ថភាពដែលសិស្សអាចប្រើប្រាស់ភាសានិងគណិតសាស្ត្រសម្រាប់យល់ដឹង ពន្យល់ បកស្រាយ ការពារអំណះអំណាង ជជែកវែកញែក សម្របសម្រួល ចរចា បញ្ចុះបញ្ចូល ស្វែងយល់និងដោះស្រាយបញ្ហា ទាំងក្នុងការសិក្សា ទាំងក្នុងការរស់នៅប្រចាំថ្ងៃ ទាំងក្នុងការបំពេញការងារវិជ្ជាជីវៈ។

### ៤.២- ភាសាបរទេស (អង់គ្លេសនិង/ឬបារាំង)

សិស្សមានសមត្ថភាពភាសាបរទេសគ្រប់គ្រាន់សម្រាប់ប្រាស្រ័យទាក់ទង ស្រាវជ្រាវ និងបន្តការសិក្សា។

### ៤.៣- បច្ចេកវិទ្យាព័ត៌មាននិងទូរគមនាគមន៍ (ICT)

សិស្សមានសមត្ថភាពខាងបច្ចេកវិទ្យាព័ត៌មាននិងទូរគមនាគមន៍។ បច្ចេកវិទ្យាព័ត៌មាននិងទូរគមនាគមន៍ ផ្តល់នូវសមត្ថភាពមូលដ្ឋានដល់ពួកគេសម្រាប់ប្រើប្រាស់កុំព្យូទ័រនិងបច្ចេកវិទ្យាព័ត៌មានក្នុងការសិក្សា និងការរស់នៅប្រចាំថ្ងៃ។

### ៤.៤- ប្រាស្រ័យទាក់ទងនិងធ្វើការងារជាក្រុម

បំណិនប្រាស្រ័យទាក់ទងនិងធ្វើការងារជាក្រុមជាសមត្ថភាពរបស់សិស្សានុសិស្សក្នុងការប្រើប្រាស់បំណិនអក្ខរពុទ្ធិនិងលេខពុទ្ធិ ដើម្បី៖(១) ផ្សព្វផ្សាយគំនិត ចំណេះដឹងជំនាញ អារម្មណ៍និងទស្សនៈ

(២) ធ្វើសុភវិនិច្ឆ័យព័ត៌មានដែលត្រូវទទួលឬមិនត្រូវទទួល ដោយឈរលើគោលការណ៍វិភាគហេតុផល និង (៣) ចរចាស្វែងរកយន្តការនិងវិធីសាស្ត្រដោះស្រាយបញ្ហាប្រកបដោយប្រសិទ្ធភាពបំផុតទៅតាមកាលៈទេសៈ ដើម្បីបានជាប្រយោជន៍ទាំងអស់គ្នា។

**៤.៥- ពិចារណានិងការបង្កើតថ្មី**

សិស្សអភិវឌ្ឍសមត្ថភាពនិងបំណិនដើម្បី៖ (១) វិភាគ យល់ពីទ្រឹស្ដីនិងបញ្ញត្តិ វាយតម្លៃព័ត៌មាន ប្រមើលមើលបញ្ហា និងពិចារណាបញ្ហាប្រកបដោយការវិភាគសមហេតុផលនិងគ្រប់ជ្រុងជ្រោយ ដើម្បីស្វែងរកដំណោះស្រាយនិងធ្វើការសម្រេចចិត្ត (២) ធ្វើនវានុវត្តន៍ បង្កើតលទ្ធភាពថ្មី និងបង្កើតគំនិតឬចំណេះដឹងថ្មី និង(៣) ជំរុញចំណង់សិក្សាដោយឯករាជ្យនិងឱ្យតម្លៃការសិក្សាពេញមួយជីវិត។

**៤.៦- អនុវត្តចំណេះដឹងនិងជំនាញ**

បំណិនអនុវត្តចំណេះដឹងនិងជំនាញ ជាសមត្ថភាពនៃការប្រើប្រាស់ចំណេះដឹងដែលសិស្សរៀនបានពីមុខវិជ្ជានីមួយៗនៅគ្រប់កម្រិតថ្នាក់ ដើម្បីជាប្រយោជន៍សម្រាប់ការរស់នៅប្រចាំថ្ងៃផង និងដើម្បីប្រែក្លាយសង្គមកម្ពុជាពីសង្គមព័ត៌មានទៅជាសង្គមចំណេះដឹង។

**៤.៧- អភិវឌ្ឍបុគ្គលគ្រួសារនិងសង្គម**

បំណិនអភិវឌ្ឍបុគ្គល គ្រួសារ និងសង្គមជាការអភិវឌ្ឍផ្នែកបញ្ញានិងស្មារតីសិស្សសម្រាប់ប្រើប្រាស់ក្នុងការរស់នៅជាពលរដ្ឋក្នុងបរិយាកាសសង្គមដែលកំពុងតែមានការប្រកួតប្រជែងនិងការផ្លាស់ប្ដូរ។ បំណិនអភិវឌ្ឍបុគ្គល គ្រួសារ និងសង្គមមានគោលបំណងអភិវឌ្ឍពលរដ្ឋឱ្យមាន៖ (១) ការទទួលខុសត្រូវក្នុងការ បំពេញភារកិច្ចចំពោះខ្លួនឯង គ្រួសារ និងសង្គម ដោយការយល់ដឹង ការស្រឡាញ់ ការដឹងគុណ និងការប្ដេជ្ញាចិត្ត (២) សីលធម៌រស់នៅ ការដឹងខុសត្រូវ ការការពារ និងការពង្រីកអំពើសុចរិតត្រឹមត្រូវជាប្រចាំ និង (៣) ភាតរភាពក្នុងការបំពេញសកម្មភាពនានាឬមានទំនាក់ទំនងជាមួយគ្នាប្រកបដោយចិត្តមេត្តានិងករុណាចំពោះគ្នាទៅវិញទៅមក ដើម្បីលើកកម្ពស់សេចក្ដីសុខនិងសុភមង្គលផ្ទាល់ខ្លួន គ្រួសារ និងសង្គម។

**៤.៨- សហគ្រិនភាពនិងភាពជាអ្នកដឹកនាំ**

សហគ្រិនភាពនិងភាពជាអ្នកដឹកនាំ គឺជាសមត្ថភាពនៃការប្រើប្រាស់ចំណេះដឹងដែលមាននៅក្នុងសមត្ថភាពសំខាន់ៗរបស់សិស្សទាំងប្រាំពីរទៀតដើម្បីជានាជោគជ័យក្នុងសកម្មភាពសេដ្ឋកិច្ចខ្នាតតូចដែលមានប្រាក់ចំណូល។

## ៥- គោលបំណងតាមមុខវិជ្ជានិងមុខវិជ្ជារង

**៥.១- ភាសាខ្មែរនិងអក្សរសាស្ត្រខ្មែរ**

ភាសាខ្មែរនិងអក្សរសាស្ត្រខ្មែរគឺជាអត្តសញ្ញាណនៃវប្បធម៌និងប្រពៃណីរបស់ជាតិខ្មែរ។ ភាសាខ្មែរជាភាសាផ្លូវការ និងជាភាសាយានក្នុងការរៀននិងបង្រៀន។ ភាសាខ្មែរនិងអក្សរសាស្ត្រខ្មែរមានសារប្រយោជន៍ក្នុងការសិក្សាស្រាវជ្រាវនិងការរស់នៅប្រចាំថ្ងៃ។

មុខវិជ្ជាភាសាខ្មែរនិងអក្សរសាស្ត្រខ្មែរ មានសមាសភាគដូចខាងក្រោម៖

- ការអាន
- ការសរសេរ
- ការស្ដាប់
- ការនិយាយ
- គោលការណ៍ប្រើប្រាស់ភាសាខ្មែរ
- ភាសាវិទ្យា អក្សរសាស្ត្រខ្មែរ និងអក្សរសិល្ប៍

គោលបំណងនៃការសិក្សាមុខវិជ្ជាភាសាខ្មែរនិងអក្សរសាស្ត្រខ្មែរគឺធានាឱ្យសិស្ស៖

- ទទួលបានចំណេះដឹងបំណិនភាសាខ្មែរនិងអក្សរសាស្ត្រខ្មែររឹងមាំ
- មានសមត្ថភាពពិពណ៌នា វិភាគ វិនិច្ឆ័យ ពន្យល់ បកស្រាយបានត្រឹមត្រូវ និងសមហេតុផល
- អនុវត្តចំណេះដឹង បំណិនភាសាខ្មែរនិងអក្សរសាស្ត្រខ្មែរក្នុងការសិក្សាមុខវិជ្ជាដទៃទៀត និងការរស់នៅប្រចាំថ្ងៃ
- ស្គាល់និងលើកកម្ពស់តម្លៃមុខវិជ្ជាភាសាខ្មែរនិងអក្សរសាស្ត្រខ្មែរ និងមានមោទនភាពក្នុងការប្រើប្រាស់ភាសាខ្មែរនិងអក្សរសាស្ត្រខ្មែរ។

**៥.២- គណិតវិទ្យា**

គណិតវិទ្យាគឺជាមុខវិជ្ជាយានដ៏សំខាន់ក្នុងការពង្រឹងនិងពង្រីកចំណេះដឹងតាមវិចារគណិតវិទ្យា ដូចជាតក្កវិទ្យា ការបកស្រាយតាមរូប វិភាគ និងការគិតអរូបី។ គណិតវិទ្យាមានសារប្រយោជន៍ក្នុងការសិក្សា មុខវិជ្ជាដទៃទៀតនិងការរស់នៅប្រចាំថ្ងៃ។

មុខវិជ្ជាគណិតវិទ្យា មានសមាសភាគដូចខាងក្រោម៖

- នព្វន្ត
- រង្វាស់រង្វាល់
- ធរណីមាត្រ
- ស្ថិតិនិងប្រូបាប
- ពីជគណិត
- គណិតវិភាគ
- ត្រីកោណមាត្រ

គោលបំណងនៃការសិក្សាមុខវិជ្ជាគណិតវិទ្យាគឺធានាឱ្យសិស្សអាច៖

- ទទួលបានចំណេះដឹងនិងបំណិនគណិតវិទ្យាមូលដ្ឋានរឹងមាំ
- មានសមត្ថភាពគិតសមហេតុផល គណនា វិភាគ ពន្យល់ បកស្រាយបានយ៉ាងរហ័ស និងត្រឹមត្រូវ
- អនុវត្តចំណេះដឹងនិងបំណិនគណិតវិទ្យាក្នុងការសិក្សាមុខវិជ្ជាដទៃទៀតនិងការរស់នៅប្រចាំថ្ងៃ

- ស្គាល់និងលើកកម្ពស់តម្លៃមុខវិជ្ជាគណិតវិទ្យានិងការអនុវត្តគណិតវិទ្យា។

**៥.៣- សិក្សាសង្គម**

សិក្សាសង្គមគឺជាបណ្តុំមុខវិជ្ជាសង្គមសាស្ត្រនិងមនុស្សសាស្ត្រ។ មុខវិជ្ជាសិក្សាសង្គមមានគោលបំណងពង្រឹងនិងពង្រីកសមត្ថភាពរបស់សិស្សជាពលរដ្ឋ ដោយការសិក្សាអំពីទ្រឹស្តីនិងការអនុវត្តពាក់ព័ន្ធនឹងអត្តសញ្ញាណវប្បធម៌ ប្រពៃណី ទំនៀមទម្លាប់ បរិស្ថាន ប្រវត្តិសាស្ត្រ ភូមិសាស្ត្រ ច្បាប់ និងនយោបាយ។

មុខវិជ្ជាសិក្សាសង្គម មានសមាសភាគដូចខាងក្រោមៈ

- ប្រវត្តិវិទ្យា
- ភូមិវិទ្យា
- សីលធម៌ពលរដ្ឋវិជ្ជា
- គេហសេដ្ឋកិច្ចវិទ្យា
- អប់រំសិល្បៈ

គោលបំណងនៃការសិក្សាមុខវិជ្ជាសិក្សាសង្គមគឺធានាឱ្យសិស្សៈ

- ទទួលបានចំណេះដឹងនិងបំណិនទាក់ទងទៅនឹងអត្តសញ្ញាណវប្បធម៌ ប្រពៃណី ច្បាប់ ទំនៀមទម្លាប់ បរិស្ថាន ប្រវត្តិសាស្ត្រ ភូមិសាស្ត្រ និងនយោបាយរបស់កម្ពុជា និងបណ្តាប្រទេសក្នុងតំបន់
- អភិវឌ្ឍបំណិនពលរដ្ឋពាក់ព័ន្ធទៅនឹងតួនាទីនិងការទទួលខុសត្រូវក្នុងនាមជាសិស្ស និងជាពលរដ្ឋទាំងនៅក្នុងសាលារៀនគ្រួសារសហគមន៍ សង្គមជាតិ និងអន្តរជាតិ
- ប្រើប្រាស់ចំណេះដឹងនិងបំណិនដែលបានមកពីការសិក្សាមុខវិជ្ជានានានៅក្នុងមុខវិជ្ជាសិក្សាសង្គមសម្រាប់ការរៀនសូត្រនិងការរស់នៅប្រចាំថ្ងៃ
- ស្រឡាញ់ជាតិធម្មជាតិ សាសនា និងព្រះមហាក្សត្រក្នុងនាមជាពលរដ្ឋដែលមានការចេះដឹងនិងការទទួលខុសត្រូវ មានមោទនភាពចំពោះជាតិរបស់ខ្លួន និងគោរពជាតិសាសន៍ដទៃ។

**៥.៤- វិទ្យាសាស្ត្រ**

វិទ្យាសាស្ត្រគឺជាបណ្តុំមុខវិជ្ជាវិទ្យាសាស្ត្រធម្មជាតិ។ មុខវិជ្ជាវិទ្យាសាស្ត្រមានគោលបំណងស្វែងយល់អំពីបាតុភូតធម្មជាតិដោយប្រើប្រាស់វិធីវិទ្យាសាស្ត្រ ដើម្បីធ្វើឱ្យចំណេះដឹងកាន់តែមានសុក្រឹតភាពសម្រាប់ប្រើប្រាស់ក្នុងការសិក្សាការរស់នៅប្រចាំថ្ងៃ និងធានាបានការអភិវឌ្ឍប្រកបដោយចីរភាព។

មុខវិជ្ជាវិទ្យាសាស្ត្រ មានសមាសភាគដូចខាងក្រោមៈ

- រូបវិទ្យា
- ផែនដីបរិស្ថានវិទ្យា
- គីមីវិទ្យា
- ជីវវិទ្យា

គោលបំណងនៃការសិក្សាមុខវិជ្ជាវិទ្យាសាស្ត្រគឺធានាឱ្យសិស្ស៖

- ទទួលបានចំណេះដឹងនិងបំណិនវិទ្យាសាស្ត្រមូលដ្ឋានរឹងមាំ ដើម្បីបម្រើឱ្យវិស័យបច្ចេកទេសនិងវិស័យផ្សេងទៀតឱ្យស្របតាមតម្រូវការទីផ្សារការងារ
- មានសមត្ថភាពគិតសមហេតុផល គណនា វិភាគ ពន្យល់ បកស្រាយបានយ៉ាងរហ័ស និងត្រឹមត្រូវតាមវិធីវិទ្យាសាស្ត្រ
- អនុវត្តចំណេះដឹងនិងបំណិនវិទ្យាសាស្ត្រក្នុងការសិក្សានិងការរស់នៅប្រចាំថ្ងៃ
- ស្គាល់និងលើកកម្ពស់តម្លៃមុខវិជ្ជាវិទ្យាសាស្ត្រនិងការអនុវត្តវិទ្យាសាស្ត្រក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។

### ៥.៥- បច្ចេកវិទ្យាព័ត៌មាននិងទូរគមនាគមន៍ (ICT)

បច្ចេកវិទ្យាព័ត៌មាននិងទូរគមនាគមន៍ជាមុខវិជ្ជាមួយសិក្សាពីការប្រើប្រាស់ឧបករណ៍បច្ចេកវិទ្យាព័ត៌មាន ដែលជាប្រយោជន៍សម្រាប់ការរៀន ការបង្រៀន និងការរស់នៅប្រចាំថ្ងៃ។

មុខវិជ្ជាបច្ចេកវិទ្យាព័ត៌មាននិងទូរគមនាគមន៍ មានសមាសភាគដូចខាងក្រោម៖

- មូលដ្ឋានគ្រឹះកុំព្យូទ័រ
- ការប្រើប្រាស់កុំព្យូទ័រប្រចាំថ្ងៃ
- កុំព្យូទ័រក្រាហ្វិក
- ការបញ្ជូនឯកសារនិងព័ត៌មានតាមប្រព័ន្ធកុំព្យូទ័រ
- បច្ចេកវិទ្យាសម្រាប់ការធ្វើបទបង្ហាញ

គោលបំណងនៃការសិក្សាមុខវិជ្ជាបច្ចេកវិទ្យាព័ត៌មាននិងទូរគមនាគមន៍គឺធានាឱ្យសិស្សអាច៖

- ទទួលបានចំណេះដឹងនិងបំណិនមូលដ្ឋានគ្រឹះកុំព្យូទ័រ
- មានសមត្ថភាពប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាននិងទូរគមនាគមន៍ សម្រាប់ទំនាក់ទំនង សហការប្រមូលនិងវិភាគទិន្នន័យសម្រាប់ការសិក្សា និងការស្រាវជ្រាវប្រកបដោយប្រសិទ្ធភាព។

### ៥.៦- ភាសាបរទេស[១] (អង់គ្លេសនិង/ឬបារាំង)

ភាសាបរទេសគឺជាមុខវិជ្ជាយានក្នុងការប្រាស្រ័យទាក់ទងនឹងការសិក្សាស្រាវជ្រាវ ការប្រកបកិច្ចការងារ ការអភិវឌ្ឍការគិត ការវិភាគ និងការច្នៃប្រឌិតដើម្បីឆ្លើយតបទៅនឹងការផ្លាស់ប្តូរសង្គម និងការជឿនលឿនផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យាក្នុងតំបន់និងសាកលលោក។ ភាសាបរទេសមានសារប្រយោជន៍យ៉ាងទូលំទូលាយក្នុងការសិក្សា ការទទួលបានការងារធ្វើ និងការរស់នៅប្រចាំថ្ងៃ។ ការបង្រៀននិងរៀនភាសាបរទេស ត្រូវអនុវត្តតាមលក្ខខណ្ឌដូចខាងក្រោម៖

- ភាសាបរទេសជាជីវភាសាទី១ (អង់គ្លេសឬបារាំង)៖ សិក្សានៅកម្រិតបឋមសិក្សានិងមធ្យមសិក្សា

(1) ចំពោះថ្នាក់ពីរភាសា (ភាសាខ្មែរ-ភាសាបរទេស «មិនមែនភាសាជនជាតិដើមភាគតិច») អាចដំណើរការបានទៅតាមលទ្ធភាពរបស់គ្រឹះស្ថានសិក្សាចាប់ពីកម្រិតបឋម រហូតដល់បញ្ចប់កម្រិតមធ្យមសិក្សាទុតិយភូមិ។

- ភាសាបរទេសជាជីវភាសាទី២(អង់គ្លេសឬបារាំង)៖ សិក្សានៅកម្រិតមធ្យមសិក្សា ដោយផ្អែកទៅតាមភាសាដែលសិស្សជ្រើសរើសនៅបឋមសិក្សា។ បើសិស្សរៀនភាសាអង់គ្លេសនៅបឋមសិក្សា សិស្សត្រូវបន្តរៀនភាសាអង់គ្លេសជាជីវភាសាទី១និងភាសាបារាំងជាជីវភាសាទី២ ឬបើក្នុងករណីផ្ទុយ គឺសិស្សត្រូវរៀនភាសាបារាំងជាជីវភាសាទី១និងភាសាអង់គ្លេសជាជីវភាសាទី២។

មុខវិជ្ជាភាសាបរទេស មានសមាសភាគដូចខាងក្រោម៖

- ការស្តាប់
- ការអាន
- ការនិយាយ
- ការសរសេរ

គោលបំណងនៃការសិក្សាមុខវិជ្ជាភាសាបរទេសគឺធានាឱ្យសិស្ស៖

- មានសមត្ថភាពទំនាក់ទំនងនៅក្នុងបំណិនទាំងបួន(ការស្តាប់ ការនិយាយ ការអាន និងការសរសេរ)
- ក្លាយជាអ្នករៀនពេញមួយជីវិតប្រកបដោយការច្នៃប្រឌិតនិងការជឿជាក់។

**៥.៧- អប់រំកាយនិងកីឡា**

អប់រំកាយនិងកីឡា គឺជាមុខវិជ្ជាមួយដែលផ្តល់ការអភិវឌ្ឍផ្លូវចិត្ត គំនិត អាកប្បកិរិយា ចំណេះដឹងក្នុងការដោះស្រាយជំងឺផ្លូវកាយនិងផ្លូវចិត្តហើយធ្វើឱ្យសិស្សមានការជឿជាក់លើខ្លួនឯងតាមរយៈសកម្មភាពរាងកាយព្រមទាំងជួយជំរុញដល់ការសិក្សាមុខវិជ្ជាផ្សេងៗទៀត។

មុខវិជ្ជាអប់រំកាយនិងកីឡា មានសមាសភាគដូចខាងក្រោម៖

- លំហាត់សមស្រប
- កាយសម្ព័ន្ធ
- អត្តពលកម្ម
- កីឡាបាល់ទាត់ បាល់បោះ បាល់ទះ
- ល្បែងប្រជាប្រិយផ្សេងៗ

គោលបំណងនៃការសិក្សាមុខវិជ្ជាអប់រំកាយនិងកីឡាគឺធានាឱ្យសិស្សមាន៖

- រាងកាយមាំមួន សុខភាពល្អ ក្តីសប្បាយ និងសុភមង្គលក្នុងជីវិត
- បំណិនចាំបាច់ក្នុងការលេងកីឡាគ្រប់ប្រភេទ
- ឥរិយាបថល្អក្នុងការប្រកួត ក៏ដូចជាក្នុងកិច្ចសហប្រតិបត្តិការ
- ការប្រុងប្រយ័ត្នចំពោះសុខភាព
- ការអំណត់ការអធ្យាស្រ័យ ភាពវាងវៃ ភាពរហ័សរហួន ឆន្ទៈមោះមុត និងមានគំនិតសមូហភាព
- ការរីកចម្រើនក្នុងការសិក្សា សណ្តាប់ធ្នាប់ និងវិន័យល្អ
- ចំណូលចិត្តហាត់ប្រាណនិងលេងកីឡា។

### ៥.៨- អប់រំសុខភាព

អប់រំសុខភាព គឺជាមុខវិជ្ជាមួយដែលសិក្សាអំពីមូលហេតុ ការបង្ការ និងការថែទាំសុខភាពបឋម គ្រប់ជ្រុងជ្រោយ ដោយឈរលើសិទ្ធិនិងយេនឌ័រជាមូលដ្ឋាន។

មុខវិជ្ជាអប់រំសុខភាព មានសមាសភាគដូចខាងក្រោម៖

- សុខភាពបឋម
- សុខភាពផ្លូវចិត្ត
- សុខភាពបន្តពូជនិងសុខភាពផ្លូវភេទ
- សុខភាពនិងបរិស្ថាន
- សុខភាពនិងជំនឿ
- សុខភាពនិងសេដ្ឋកិច្ច

គោលបំណងនៃការសិក្សាមុខវិជ្ជាអប់រំសុខភាពគឺធានាឱ្យសិស្សមាន៖

- ចំណេះដឹងសុខភាពស្របតាមការលូតលាស់រាងកាយនិងស្មារតីប្រកបដោយលក្ខណៈ វិទ្យាសាស្ត្រ
- បំណិនសម្រាប់បង្ការជំងឺឆ្លង ជំងឺមិនឆ្លង គ្រោះថ្នាក់ផ្សេងៗ និងវិធីជួយសង្គ្រោះបឋម
- គុណតម្លៃនិងឥរិយាបថដែលនាំឱ្យពួកគេអភិវឌ្ឍខ្លួនប្រកបដោយសុខភាពពេញលេញ ទាំងកាយប្រាជ្ញាស្មារតីនិងចេះទទួលខុសត្រូវរាល់ទង្វើរបស់ខ្លួន។

### ៥.៩- អប់រំសិល្បៈ

ការអប់រំសិល្បៈ ជាបណ្តុំមុខវិជ្ជាដែលជួយអភិវឌ្ឍវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា តាមរយៈការផ្តោតយកចិត្តទុកដាក់រៀនតន្ត្រី ចម្រៀង របាំ គំនូរ និងហត្ថកម្មប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ការប្រាស្រ័យទាក់ទងគ្នា គំនិតច្នៃប្រឌិត ការចេះអត់ឱនឱ្យគ្នាទៅវិញទៅមក ការស្រឡាញ់សោភ័ណភាពក្នុងចិត្តអារម្មណ៍ ព្រមទាំងចូលរួមអភិរក្សនិងអភិវឌ្ឍវប្បធម៌ខ្មែរឱ្យគង់វង្ស។

មុខវិជ្ជាអប់រំសិល្បៈ មានសមាសភាគដូចខាងក្រោម៖

- ចម្រៀង
- របាំ
- ការលេងឧបករណ៍តន្ត្រី
- គំនូរនិងគំនូស
- ហត្ថកម្ម
- ការផ្តល់គុណតម្លៃ (តន្ត្រី គំនូរ និងហត្ថកម្ម)

គោលបំណងនៃការសិក្សាមុខវិជ្ជាអប់រំសិល្បៈគឺធានាឱ្យសិស្ស៖

- អភិវឌ្ឍវិជ្ជាសម្បទានិងបំណិនសម្បទាមូលដ្ឋានដល់សិស្សតាមរយៈការសម្តែង និង ការផ្តល់គុណតម្លៃដល់សិល្បៈ
- មាន គំនិតច្នៃប្រឌិត បំណិនសម្បទាសម្រាប់ការប្រាស្រ័យទាក់ទងគ្នាមានសុភ វិនិច្ឆ័យ តាមរយៈការសម្តែងនិងការផ្តល់គុណតម្លៃដល់សិល្បៈ

- គោរពនិងផ្តល់តម្លៃដល់វប្បធម៌ជាតិនិងអន្តរជាតិ ព្រមទាំងចេះរិះរកមធ្យោបាយដោះស្រាយលើបញ្ហាប្រឈម ដោយឈរលើស្មារតីសហការយ៉ាងជិតស្និទ្ធទាំងក្នុងនិងក្រៅសហគមន៍។

**៥.១០- បំណិនជីវិតតាមមូលដ្ឋាន**

មុខវិជ្ជាបំណិនជីវិតតាមមូលដ្ឋាននេះ គឺផ្តល់ឱ្យអ្នកសិក្សាមានឱកាសក្នុងការទទួលបានផ្នែកចំណេះដឹង បំណិន និងការចូលរួមលើកកម្ពស់ជីវភាពគ្រួសារនិងសង្គម។

មុខវិជ្ជាបំណិនជីវិតតាមមូលដ្ឋាន មានសមាសភាគដូចខាងក្រោម៖

- កសិកម្ម
- សេវាកម្ម
- សិប្បកម្មខ្នាតតូចនិងផ្នែកផ្សេងៗទៀត

គោលបំណងនៃការសិក្សាមុខវិជ្ជាបំណិនជីវិតតាមមូលដ្ឋានគឺធានាឱ្យសិស្ស៖

- មានបំណិន បញ្ញា បុគ្គលិកលក្ខណៈអន្តរបុគ្គលនិងវិជ្ជាជីវៈដែលអាចជួយដល់ការសម្រេចចិត្ត ការធ្វើទំនាក់ទំនងប្រកបដោយប្រសិទ្ធភាព អាចដោះស្រាយនិងគ្រប់គ្រងខ្លួនឯងបាន និងមានសហគ្រិនភាព
- លើកស្ទួយសុខុមាលភាពនិងជីវិតប្រកបដោយផលិតភាព។

## ៦- មុខវិជ្ជាសិក្សានិងម៉ោងសិក្សាតាមភូមិសិក្សា

កម្មវិធីសិក្សាត្រូវកំណត់ឱ្យបង្រៀនចំនួន៣៥សប្តាហ៍ក្នុងមួយឆ្នាំសិក្សា។

### ៦.១- មត្តេយ្យសិក្សា

**ក- សមត្ថភាពរំពឹងទុក**

ក្រោយពេលបញ្ចប់ការសិក្សានៅមត្តេយ្យសិក្សា កុមារតូចនឹងទទួលបាន៖

**វិជ្ជាសម្បទា**

- ស្គាល់និងចេះអាន ព្យញ្ជនៈ ស្រៈ ព្យាង្គ ពាក្យ ឃ្លា និងល្បះ
- រាប់ចំនួន លេខ គូសតាមលេខពីរខ្ទង់ ស្គាល់រូបរាងវត្ថុផ្សេងៗ ទំហំ និងរង្វាស់។

**បំណិនសម្បទា**

- ចេះប្រើភាសាខ្មែរសម្រាប់និយាយ ស្តាប់ និងទំនាក់ទំនង
- ចេះប្រើប្រាស់គណិតវិទ្យា (រាប់ គូសតាម និងប្រៀបធៀប)
- ចេះអនាម័យខ្លួនប្រាណ
- ចេះប្រើប្រាស់ចលករតូច (ចលនាម្រាមដៃ) និងចលករធំ (រាងកាយ)
- ចេះផ្តល់ហេតុផលចំពោះទង្វើរបស់ខ្លួន
- ចេះប្រើប្រាស់ពាក្យសម្តីនិងកាយវិការសមរម្យជាមួយមិត្តភក្តិ គ្រួសារ និងអ្នកដទៃ
- ស្គាល់ខុស ស្គាល់ត្រូវ។

**ចរិយាសម្បទា**

- ចូលចិត្តការសិក្សា ចេះឆ្ងល់ និងចង់ស្វែងយល់ពីអ្វីដែលថ្មីនិងប្លែក
- ចេះជួយចែករំលែកនិងសហការគ្នា
- ចូលចិត្តចម្រៀង របាំ និងតន្ត្រីប្រពៃណីខ្មែរ
- ស្រឡាញ់បរិស្ថានស្អាត
- ស្រឡាញ់ខ្លួនឯង គ្រួសារ មិត្តភក្តិ គ្រូបង្រៀន និងអ្នកដទៃ។

**ខ- មុខវិជ្ជា**

ចិត្តចលភាពបុរេគណិតភាសាខ្មែរវិទ្យាសាស្ត្រ (ទស្សនា សង្កេត ពិសោធ) សិក្សាសង្គម (ចម្រៀង គំនូរ សកម្មភាពកសាង សកម្មភាពប្រចាំថ្ងៃ ល្បែង និងអនាម័យនៅផ្ទះ)។

**គ- ម៉ោងសិក្សា**

តារាងរបាយមុខវិជ្ជានិងម៉ោងសិក្សា

**តារាង១ : របាយមុខវិជ្ជានិងម៉ោងសិក្សាសម្រាប់មត្តេយ្យសិក្សា**

| ល.រ. | មុខវិជ្ជា | ថ្នាក់ | | |
|---|---|---|---|---|
| | | កម្រិតទាប | កម្រិតមធ្យម | កម្រិតខ្ពស់ |
| ១ | ចិត្តចលភាព | ៦ | ៦ | ៦ |
| ២ | បុរេគណិត | ៣ | ៣ | ៣ |
| ៣ | បុរេសំណេរ | ៤ | ៤ | ៤ |
| ៤ | វិទ្យាសាស្ត្រ | ៣ | ៣ | ៣ |
| ៥ | សិក្សាសង្គម | ១៤ | ១៤ | ១៤ |
| **សរុបម៉ោងសិក្សាប្រចាំសប្តាហ៍** | | ៣០ | ៣០ | ៣០ |

**សម្គាល់** : ៥ថ្ងៃក្នុងមួយសប្តាហ៍ ៦ម៉ោងសិក្សាក្នុងមួយថ្ងៃ និង១ម៉ោងសិក្សាមានរយៈពេល៣០នាទី។

**៦.២- បឋមសិក្សា**

**ក- សមត្ថភាពរំពឹងទុក**

ក្រោយពេលបញ្ចប់ការសិក្សានៅបឋមសិក្សា សិស្សនឹងទទួលបានៈ

**វិជ្ជាសម្បទា**

- មានចំណេះដឹងមូលដ្ឋានគ្រឹះរឹងមាំផ្នែកភាសាខ្មែរ សិក្សាសង្គម គណិតវិទ្យា និងអភិវឌ្ឍសុខភាពកាយសម្បទានិងសីលធម៌
- មានចំណេះដឹងមូលដ្ឋានគ្រឹះផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យាព័ត៌មាននិងទូរគមនាគមន៍ (ICT) និងភាសាបរទេស។

**បំណិនសម្បទា**

- មានបំណិនមូលដ្ឋានផ្នែកភាសាខ្មែរ (ការអាន ការសរសេរ ការនិយាយ និងការស្ដាប់)
- មានបំណិនមូលដ្ឋានផ្នែកគណិតវិទ្យា (គណនា ប្រៀបធៀប និងដោះស្រាយបញ្ហា)
- មានបំណិនប្រើប្រាស់ចំណេះដឹងវិទ្យាសាស្ត្រមូលដ្ឋាន
- មានបំណិនត្រិះរិះពិចារណាមូលដ្ឋានក្នុងការសិក្សា
- មានបំណិនប្រាស្រ័យទាក់ទងល្អក្នុងការសិក្សានិងក្នុងសង្គម
- មានបំណិនបង្ការនិងថែទាំសុខភាពបឋម
- មានសមត្ថភាពស្គាល់ខុស ស្គាល់ត្រូវ។

**ចរិយាសម្បទា**

- ស្រឡាញ់និងផ្ដល់តម្លៃដល់ការសិក្សាក្នុងសាលារៀន
- ស្គាល់និងឱ្យតម្លៃសន្ដានចិត្តមេត្តានិងករុណាចំពោះគ្រួសារ មិត្តភក្តិ និងអ្នកដទៃ
- ស្គាល់ ស្រឡាញ់ ថែរក្សា និងការពារវប្បធម៌ ប្រពៃណី ទំនៀមទម្លាប់ និងសិល្បៈជាតិ តំបន់ និងអន្តរជាតិ
- ស្រឡាញ់និងឱ្យតម្លៃបរិស្ថាន វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា
- ស្រឡាញ់ភាពស្អាតបាត ទាំងខ្លួនប្រាណ សាលារៀន ផ្ទះសម្បែង និងទីសាធារណៈ
- មានទម្លាប់និងអនុវត្តការរស់នៅប្រកបដោយសុខភាពតាមរយៈការធ្វើពលកម្ម និងហាត់កីឡា
- ទទួលខុសត្រូវចំពោះទង្វើខ្លួនឯងទាំងក្នុងការសិក្សានិងការរស់នៅប្រចាំថ្ងៃ។

**ខ- មុខវិជ្ជា**

ភាសាខ្មែរ គណិតវិទ្យា វិទ្យាសាស្ត្រ មូលដ្ឋានគ្រឹះកុំព្យូទ័រ សិក្សាសង្គម អប់រំសិល្បៈ អប់រំកាយនិង កីឡា អប់រំសុខភាព ភាសាបរទេស បំណិនជីវិតតាមមូលដ្ឋាន។

**គ- ម៉ោងសិក្សា**

តារាងរបាយមុខវិជ្ជានិងម៉ោងសិក្សាថ្នាក់ពីទី១ដល់ថ្នាក់ទី៦

**តារាង២ : របាយមុខវិជ្ជានិងម៉ោងសិក្សាពីថ្នាក់ទី១ដល់ថ្នាក់ទី៦**

| ល.រ. | មុខវិជ្ជា | ថ្នាក់ | | | | | |
|---|---|---|---|---|---|---|---|
| | | ១ | ២ | ៣ | ៤ | ៥ | ៦ |
| ១ | ភាសាខ្មែរ | ១១ | ១១ | ១១ | ៩ | ៩ | ៩ |
| ២ | គណិតវិទ្យា | ៧ | ៧ | ៧ | ៦ | ៦ | ៦ |
| ៣ | វិទ្យាសាស្ត្រ | ៣ | ៣ | ៣ | ៣ | ៣ | ៣ |
| ៤ | កុំព្យូទ័រ | ០ | ០ | ០ | ១ | ១ | ១ |
| ៥ | សិក្សាសង្គម | ៣ | ៣ | ៣ | ៣ | ៣ | ៣ |
| ៦ | អប់រំសិល្បៈ | ១ | ១ | ១ | ១ | ១ | ១ |
| ៧ | អប់រំកាយនិងកីឡា | ២ | ២ | ២ | ២ | ២ | ២ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៨ | អប់រំសុខភាព | ១ | ១ | ១ | ១ | ១ | ១ |
| ៩ | ភាសាបរទេស | ២ | ២ | ២ | ២ | ២ | ២ |
| ១០ | បំណិនជីវិតតាមមូលដ្ឋាន | ០ | ០ | ០ | ២ | ២ | ២ |
| **សរុបម៉ោងសិក្សាប្រចាំសប្តាហ៍** | | ៣០ | ៣០ | ៣០ | ៣០ | ៣០ | ៣០ |

**សម្គាល់** : ៦ថ្ងៃក្នុងមួយសប្តាហ៍ ៥ម៉ោងសិក្សាក្នុងមួយថ្ងៃ និង១ម៉ោងសិក្សាមានរយៈពេល៤០នាទី។

### ៦.៣- មធ្យមសិក្សាបឋមភូមិ

#### ក- សមត្ថភាពរំពឹងទុក

ក្រោយពេលបញ្ចប់ការសិក្សានៅមធ្យមសិក្សាបឋមភូមិ សិស្សនឹងទទួលបាន៖

**វិជ្ជាសម្បទា**

- មានចំណេះដឹងមូលដ្ឋានគ្រឹះរឹងមាំផ្នែកភាសាខ្មែរ វិទ្យាសាស្ត្រ វិទ្យាសាស្ត្រសង្គម គណិតវិទ្យា និងអភិវឌ្ឍសុខភាព កាយសម្បទា និងសីលធម៌
- មានចំណេះដឹងមូលដ្ឋានគ្រឹះផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យាព័ត៌មាននិងទូរគមនាគមន៍ (ICT) និងភាសាបរទេស។

**បំណិនសម្បទា**

- មានបំណិនមូលដ្ឋានរឹងមាំនិងទូលំទូលាយផ្នែកភាសាខ្មែរ (ការអាន ការសរសេរ ការនិយាយ និងការស្តាប់)
- មានបំណិនមូលដ្ឋានរឹងមាំផ្នែកគណិតវិទ្យា(គណនា ប្រៀបធៀប ពន្យល់ បកស្រាយ និងដោះស្រាយបញ្ហា)
- មានបំណិនប្រើប្រាស់ចំណេះដឹងវិទ្យាសាស្ត្រ បច្ចេកវិទ្យាព័ត៌មាននិងទូរគមនាគមន៍ (ICT) មូលដ្ឋាន
- មានបំណិនត្រិះរិះពិចារណានិងដោះស្រាយបញ្ហាមូលដ្ឋានក្នុងការសិក្សានិងក្នុងសង្គម
- មានបំណិនប្រាស្រ័យទាក់ទងទូលំទូលាយ សម្រាប់ការសិក្សានិងការរស់នៅប្រចាំថ្ងៃ
- មានបំណិនបង្ការនិងថែទាំសុខភាពបឋម
- មានសមត្ថភាពស្គាល់ខុស ស្គាល់ត្រូវ។

**ចរិយាសម្បទា**

- ស្រឡាញ់និងផ្តល់តម្លៃដល់ការសិក្សាទាំងក្នុងនិងក្រៅប្រព័ន្ធ
- ស្គាល់និងឱ្យតម្លៃសន្តានចិត្តមេត្តានិងករុណាចំពោះគ្រួសារ មិត្តភក្តិ និងអ្នកដទៃ
- ស្គាល់ ស្រឡាញ់ ថែរក្សា និងការពារវប្បធម៌ ប្រពៃណី ទំនៀមទម្លាប់ និងសិល្បៈជាតិ តំបន់ និងអន្តរជាតិ
- ស្រឡាញ់និងឱ្យតម្លៃបរិស្ថាន វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា
- ស្រឡាញ់ភាពស្អាតបាត ទាំងខ្លួនប្រាណ សាលារៀន ផ្ទះសម្បែង និងទីសាធារណៈ

- មានទម្លាប់និងអនុវត្តការរស់នៅប្រកបដោយសុខភាពតាមរយៈការធ្វើពលកម្មនិងហាត់កីឡា
- ទទួលខុសត្រូវចំពោះទង្វើរបស់ខ្លួនឯង និងរបស់ក្រុមទាំងក្នុងការសិក្សា និងការរស់នៅប្រចាំថ្ងៃ។

**ខ- មុខវិជ្ជា**

ភាសាខ្មែរ(សរសេរតាមអាន តែងសេចក្ដី វេយ្យាករណ៍ មេសូត្រ សិក្សាអត្ថបទ) គណិតវិទ្យា វិទ្យាសាស្ត្រ (រូបវិទ្យា ផែនដីបរិស្ថានវិទ្យា គីមីវិទ្យា ជីវវិទ្យា) សិក្សាសង្គម (ប្រវត្តិវិទ្យា ភូមិវិទ្យា សីលធម៌ពលរដ្ឋវិជ្ជា គេហសេដ្ឋកិច្ចវិទ្យា) បច្ចេកវិទ្យាព័ត៌មាននិងទូរគមនាគមន៍(ICT) ភាសាបរទេស អប់រំសិល្បៈ អប់រំកាយនិងកីឡា អប់រំសុខភាព បំណិនជីវិតតាមមូលដ្ឋាន។

**គ- ម៉ោងសិក្សា**

តារាងរបាយមុខវិជ្ជានិងម៉ោងសិក្សាពីថ្នាក់ទី៧ដល់ថ្នាក់ទី៩

**តារាង៣ : របាយមុខវិជ្ជានិងម៉ោងសិក្សាពីថ្នាក់ទី៧ដល់ថ្នាក់ទី៩**

| ល.រ. | មុខវិជ្ជា | ថ្នាក់ | | |
|---|---|---|---|---|
| | | ៧ | ៨ | ៩ |
| ១ | ភាសាខ្មែរ | ៧ | ៧ | ៧ |
| ២ | ភាសាបរទេស | ៦ | ៦ | ៦ |
| ៣ | គណិតវិទ្យា | ៧ | ៧ | ៧ |
| ៤ | វិទ្យាសាស្ត្រ | ៦ | ៦ | ៦ |
| ៥ | សិក្សាសង្គម | ៧ | ៧ | ៧ |
| ៦ | បច្ចេកវិទ្យាព័ត៌មាននិងទូរគមនាគមន៍ (ICT) | ២ | ២ | ២ |
| ៧ | អប់រំកាយនិងកីឡា | ២ | ២ | ២ |
| ៨ | អប់រំសិល្បៈ | ១ | ១ | ១ |
| ៩ | អប់រំសុខភាព | ១ | ១ | ១ |
| ១០ | បំណិនជីវិតតាមមូលដ្ឋាន | ១ | ១ | ១ |
| **សរុបម៉ោងសិក្សាប្រចាំសប្ដាហ៍** | | ៤០ | ៤០ | ៤០ |

**សម្គាល់** : - ៦ថ្ងៃក្នុងមួយសប្ដាហ៍ ពី៤ទៅ៧ម៉ោងសិក្សាក្នុងមួយថ្ងៃ និង១ម៉ោងសិក្សាមានរយៈពេល៥០នាទី។
- ជីវភាសាទី១ ៤ម៉ោងសិក្សា និង២ម៉ោងសិក្សាសម្រាប់ជីវភាសាទី២។

## ៦.៤- មធ្យមសិក្សាទុតិយភូមិ

### ក- សមត្ថភាពរំពឹងទុក

ក្រោយពេលបញ្ចប់ការសិក្សានៅមធ្យមសិក្សាទុតិយភូមិ សិស្សនឹងទទួលបាន៖

**វិជ្ជាសម្បទា**

- មានចំណេះដឹងមូលដ្ឋានគ្រឹះរឹងមាំផ្នែកអក្សរសាស្ត្រខ្មែរ វិទ្យាសាស្ត្រសង្គម គណិតវិទ្យា និង អភិវឌ្ឍសុខភាព កាយសម្បទា និងសីលធម៌
- មានចំណេះដឹងមូលដ្ឋានគ្រឹះរឹងមាំផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាព័ត៌មាននិងទូរគមនាគមន៍ (ICT) និងភាសាបរទេស។

**បំណិនសម្បទា**

- មានបំណិនមូលដ្ឋានរឹងមាំ ច្បាស់លាស់ និងទូលំទូលាយផ្នែកអក្សរសាស្ត្រខ្មែរ (ប្រៀបធៀប ពន្យល់ វិភាគ បកស្រាយ និងដោះស្រាយបញ្ហា)
- មានបំណិនមូលដ្ឋានរឹងមាំនិងច្បាស់លាស់ផ្នែកគណិតវិទ្យា(គណនា ប្រៀបធៀប ពន្យល់ រិះគន់ បកស្រាយ និងដោះស្រាយបញ្ហា)
- មានបំណិនអនុវត្តចំណេះដឹងវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាព័ត៌មាននិងទូរគមនាគមន៍ (ICT) មូលដ្ឋាន
- មានបំណិនត្រិះរិះពិចារណានិងដោះស្រាយបញ្ហារឹងមាំនិងទូលំទូលាយទាំងក្នុងការសិក្សា និងក្នុងសង្គម
- មានបំណិនប្រាស្រ័យទាក់ទងទូលំទូលាយនិងមានប្រសិទ្ធភាពក្នុងការសិក្សានិងក្នុងសង្គម
- មានបំណិនបង្ការនិងថែទាំសុខភាពបឋម
- មានសមត្ថភាពនិងសីលធម៌ក្នុងការការពារ និងពង្រីកភាពត្រឹមត្រូវ។

**ចរិយាសម្បទា**

- ស្រឡាញ់និងផ្តល់តម្លៃដល់ការសិក្សាពេញមួយជីវិត
- ស្គាល់និងឱ្យតម្លៃសន្តានចិត្តមេត្តានិងករុណាចំពោះគ្រួសារ មិត្តភក្តិ និងអ្នកដទៃ
- អភិរក្សនិងអភិវឌ្ឍវប្បធម៌ ប្រពៃណី ទំនៀមទម្លាប់ និងសិល្បៈជាតិ តំបន់ និងអន្តរជាតិ
- ស្រឡាញ់និងឱ្យតម្លៃខ្ពស់ដល់បរិស្ថាន វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា
- ស្រឡាញ់ភាពស្អាតបាត ទាំងខ្លួនប្រាណ សាលារៀន ផ្ទះសម្បែង និងទីសាធារណៈ
- មានទម្លាប់និងអនុវត្តការរស់នៅប្រកបដោយសុខភាពតាមរយៈការធ្វើពលកម្មនិងហាត់កីឡា
- ទទួលខុសត្រូវចំពោះទង្វើរបស់ខ្លួនឯងនិងរបស់ក្រុម ទាំងក្នុងការសិក្សានិងការរស់នៅប្រចាំថ្ងៃ។

**ខ- មុខវិជ្ជា**

អក្សរសាស្ត្រខ្មែរ គណិតវិទ្យា ភាសាបរទេស អប់រំកាយនិងកីឡា វិទ្យាសាស្ត្រ (រូបវិទ្យា ផែនដីបរិស្ថានវិទ្យា គីមីវិទ្យា ជីវវិទ្យា) សិក្សាសង្គម (ប្រវត្តិវិទ្យា ភូមិវិទ្យា សីលធម៌ពលរដ្ឋវិជ្ជា គេហសេដ្ឋកិច្ចវិទ្យា) បច្ចេកវិទ្យាព័ត៌មាននិងទូរគមនាគមន៍ (ICT) និងអប់រំសុខភាព។

**គ- ម៉ោងសិក្សា**

តារាងរបាយមុខវិជ្ជានិងម៉ោងសិក្សាថ្នាក់ទី១០ ទី១១ និងទី១២

បណ្តុំវិទ្យាសាស្ត្រ

**តារាង៤ : របាយមុខវិជ្ជានិងម៉ោងសិក្សាថ្នាក់ទី១០ ទី១១ និងទី១២ បណ្តុំវិទ្យាសាស្ត្រ**

| ល.រ. | មុខវិជ្ជា | ថ្នាក់ | | |
|---|---|---|---|---|
| | | ១០ | ១១ | ១២ |
| ១ | អក្សរសាស្ត្រខ្មែរ | ៥ | ៥ | ៥ |
| ២ | គណិតវិទ្យា | ៦ | ៦ | ៦ |
| ៣ | ភាសាបរទេស | ៦ | ៦ | ៦ |
| ៤ | អប់រំកាយនិងកីឡា | ២ | ២ | ២ |
| ៥ | គេហសេដ្ឋកិច្ចវិទ្យា | ១ | ១ | ១ |
| ៦ | រូបវិទ្យា | ៤ | ៤ | ៤ |
| ៧ | ផែនដីបរិស្ថានវិទ្យា | ២ | ២ | ២ |
| ៨ | គីមីវិទ្យា | ៣ | ៣ | ៣ |
| ៩ | ជីវវិទ្យា | ៣ | ៣ | ៣ |
| ១០ | ប្រវត្តិវិទ្យា | ២ | ២ | ២ |
| ១១ | ភូមិវិទ្យា | ២ | ២ | ២ |
| ១២ | សីលធម៌ពលរដ្ឋវិជ្ជា | ២ | ២ | ២ |
| ១៣ | បច្ចេកវិទ្យាព័ត៌មាននិងទូរគមនាគមន៍ (ICT) | ១ | ១ | ១ |
| ១៤ | អប់រំសុខភាព | ១ | ១ | ១ |
| **សរុបម៉ោងសិក្សាប្រចាំសប្តាហ៍** | | **៤០** | **៤០** | **៤០** |

សម្គាល់ : - ៦ថ្ងៃក្នុងមួយសប្តាហ៍ ពី៤ទៅ៧ម៉ោងសិក្សាក្នុងមួយថ្ងៃ និង១ម៉ោងសិក្សាមានរយៈពេល៥០នាទី។

- ជីវភាសាទី១ ៤ម៉ោងសិក្សា និង២ម៉ោងសិក្សាសម្រាប់ជីវភាសាទី២។

## បណ្តុំវិទ្យាសាស្ត្រសង្គម

តារាង៥ : របាយមុខវិជ្ជានិងម៉ោងសិក្សាថ្នាក់ទី១០ ទី១១ និងទី១២ បណ្តុំវិទ្យាសាស្ត្រសង្គម

| ល.រ. | មុខវិជ្ជា | ថ្នាក់ | | |
|---|---|---|---|---|
| | | ១០ | ១១ | ១២ |
| ១ | អក្សរសាស្ត្រខ្មែរ | ៦ | ៦ | ៦ |
| ២ | គណិតវិទ្យា | ៥ | ៥ | ៥ |
| ៣ | ភាសាបរទេស | ៦ | ៦ | ៦ |
| ៤ | អប់រំកាយនិងកីឡា | ២ | ២ | ២ |
| ៥ | គេហសេដ្ឋកិច្ចវិទ្យា | ១ | ១ | ១ |
| ៦ | រូបវិទ្យា | ២ | ២ | ២ |
| ៧ | ផែនដីបរិស្ថានវិទ្យា | ២ | ២ | ២ |
| ៨ | គីមីវិទ្យា | ២ | ២ | ២ |
| ៩ | ជីវវិទ្យា | ២ | ២ | ២ |
| ១០ | ប្រវត្តិវិទ្យា | ៤ | ៤ | ៤ |
| ១១ | ភូមិវិទ្យា | ៣ | ៣ | ៣ |
| ១២ | សីលធម៌ពលរដ្ឋវិជ្ជា | ៣ | ៣ | ៣ |
| ១៣ | បច្ចេកវិទ្យាព័ត៌មាននិងទូរគមនាគមន៍ (ICT) | ១ | ១ | ១ |
| ១៤ | អប់រំសុខភាព | ១ | ១ | ១ |
| សរុបម៉ោងសិក្សាប្រចាំសប្តាហ៍ | | ៤០ | ៤០ | ៤០ |

សម្គាល់ : - ៦ថ្ងៃក្នុងមួយសប្តាហ៍ ពី៤ទៅ៧ម៉ោងសិក្សាក្នុងមួយថ្ងៃ និង១ម៉ោងសិក្សាមានរយៈពេល៥០នាទី។

- ជីវភាសាទី១ ៤ម៉ោងសិក្សា និង២ម៉ោងសិក្សាសម្រាប់ជីវភាសាទី២។

### ៦.៥- ការអប់រំបច្ចេកទេស

**ក- សមត្ថភាពរំពឹងទុក**

ក្រោយពីបញ្ចប់ការសិក្សាការអប់រំបច្ចេកទេស សិស្សនឹងអាចៈ

**វិជ្ជាសម្បទា**

- ទទួលបានចំណេះដឹងមូលដ្ឋានវិទ្យាសាស្ត្រដែលទាក់ទងនឹងមុខវិជ្ជាជំនាញ
- បកស្រាយបញ្ញត្តិមូលដ្ឋានគ្រឹះនៃមុខជំនាញឯកទេសនីមួយៗ។

**បំណិនសម្បទា**

- អនុវត្តជំនាញឯកទេសដែលទទួលបានពីការបណ្តុះបណ្តាលប្រកបដោយប្រសិទ្ធភាព
- ប្រតិបត្តិគ្រឿងម៉ាស៊ីននិងឧបករណ៍ពាក់ព័ន្ធផ្សេងៗបាន។

**ចរិយាសម្បទា**

- មានស្មារតីទទួលខុសត្រូវនិងម្ចាស់ការលើការងាររបស់ខ្លួន

- មានគំនិតច្នៃប្រឌិតថ្មីដើម្បីអាចដោះស្រាយបញ្ហាបាន
- ស្រឡាញ់ការងារប្រតិបត្តិនិងធ្វើការជាក្រុមប្រកបដោយប្រសិទ្ធភាព
- អភិវឌ្ឍបុគ្គលិកលក្ខណៈនិងមុខរបរ
- មានស្មារតីអភិវឌ្ឍសង្គមជាតិប្រកបដោយចីរភាព។

**ខ- មុខវិជ្ជា**

ការអប់រំបច្ចេកទេសមានមុខវិជ្ជាពីរ គឺមុខវិជ្ជាចំណេះទូទៅនិងមុខវិជ្ជាវិជ្ជាជីវៈ។ មុខវិជ្ជាចំណេះទូទៅរួមមាន អក្សរសាស្ត្រខ្មែរ ភាសាអង់គ្លេស គណិតវិទ្យា កុំព្យូទ័រ សីលធម៌ពលរដ្ឋវិជ្ជា កីឡា វិទ្យាសាស្ត្រ(រូបវិទ្យា ផែនដីបរិស្ថានវិទ្យា គីមីវិទ្យា ជីវវិទ្យា) វិទ្យាសាស្ត្រសង្គម (ប្រវត្តិវិទ្យា ភូមិវិទ្យា គេហសេដ្ឋកិច្ចវិទ្យា)។ មុខវិជ្ជាវិជ្ជាជីវៈរួមមានមុខវិជ្ជាបច្ចេកទេសវិជ្ជាជីវៈ និងមុខវិជ្ជាវិជ្ជាជីវៈតាមតំបន់។ ការអប់រំបច្ចេកទេសនេះរួមបញ្ចូលទាំងសកម្មភាពជម្រើសនិងកម្មសិក្សា។

**គ- ម៉ោងសិក្សា**

**តារាង៦ : របាយមុខវិជ្ជានិងម៉ោងសិក្សាឆ្នាំទី១ ឆ្នាំទី២ និងឆ្នាំទី៣**

| មុខវិជ្ជា | | | ឆ្នាំទី១ | ឆ្នាំទី២ | ឆ្នាំទី៣ |
|---|---|---|---|---|---|
| មុខវិជ្ជាចំណេះទូទៅ | អក្សរសាស្ត្រខ្មែរ | | ១១៤ម៉ោង | ១១៤ម៉ោង | ១១៤ម៉ោង |
| | ភាសាអង់គ្លេស | | ៧៦ម៉ោង | ៧៦ម៉ោង | ៧៦ម៉ោង |
| | គណិតវិទ្យា | | ១១៤ម៉ោង | ១១៤ម៉ោង | ១១៤ម៉ោង |
| | កុំព្យូទ័រ | | ៧៦ម៉ោង | ៧៦ម៉ោង | ៧៦ម៉ោង |
| | សីលធម៌ពលរដ្ឋវិជ្ជា | | ៣៨ម៉ោង | ៣៨ម៉ោង | ០ម៉ោង |
| | កីឡា | | ៣២ម៉ោង | ៣២ម៉ោង | ៣២ម៉ោង |
| | វិទ្យាសាស្ត្រឬវិទ្យាសាស្ត្រសង្គម | រូបវិទ្យា(១) | ៧៦ម៉ោង | ៧៦ម៉ោង | ៧៦ម៉ោង |
| | | គីមីវិទ្យាជីវវិទ្យា(២) | ៧៦ម៉ោង | ៧៦ម៉ោង | ៧៦ម៉ោង |
| | | សេដ្ឋកិច្ច(៣) | ៧៦ម៉ោង | ៧៦ម៉ោង | ៧៦ម៉ោង |
| | | ប្រវត្តិវិទ្យា-ភូមិវិទ្យា | ៧៦ម៉ោង | ៧៦ម៉ោង | ៧៦ម៉ោង |
| | សរុប | | ៥២៦ម៉ោង | ៥២៦ម៉ោង | ៤៨០ម៉ោង |
| មុខវិជ្ជាវិជ្ជាជីវៈ | មុខវិជ្ជាបច្ចេកទេសវិជ្ជាជីវៈ | | ៧៤៩-៧៦៩ម៉ោង | ៧៤៩-៧៦៩ម៉ោង | ៧៤៩-៧៦៩ម៉ោង |
| | មុខវិជ្ជាវិជ្ជាជីវៈតាមតំបន់ | | ៨០-១០០ម៉ោង | ៨០-១០០ម៉ោង | ៨០-១០០ម៉ោង |
| | **សរុប** | | **៨៤៨ម៉ោង** | **៨៤៨ម៉ោង** | **៨៤៨ម៉ោង** |
| សកម្មភាពជម្រើស | | | ៦ម៉ោង | ៦ម៉ោង | ៦ម៉ោង |
| កម្មសិក្សា | | | | | ៣២០ម៉ោង (មិនរាប់បញ្ចូល) |
| **សរុបរួម** | | | **១៣៨០ម៉ោង** | **១៣៨០ម៉ោង** | **១៣៣៤** |

**សម្គាល់** : សិក្សា៦ថ្ងៃក្នុងមួយសប្តាហ៍ ពី៤ទៅ៦ម៉ោងសិក្សាក្នុងមួយថ្ងៃ ១ម៉ោងសិក្សារយៈពេល៥០នាទី ១ឆ្នាំសិក្សារយៈពេល៣៨សប្តាហ៍។

(១) *ត្រូវរៀនមុខវិជ្ជារូបវិទ្យា ចំនួន២ម៉ោងសិក្សាក្នុង១សប្តាហ៍ លើមុខជំនាញមេកានិចអេឡិចត្រូនិចឬអគ្គិសនី ដែលមានចំនួន៧៦ម៉ោងក្នុងមួយឆ្នាំ*

(២) *ត្រូវរៀនមុខវិជ្ជាគីមីវិទ្យា/ជីវវិទ្យា ចំនួន២ម៉ោងក្នុង១សប្តាហ៍ លើមុខជំនាញក្សេត្រសាស្ត្រឬបសុវប្បកម្ម ដែលមានចំនួន៧៦ម៉ោងក្នុងមួយឆ្នាំ*

(៣) *ត្រូវរៀនមុខវិជ្ជាសេដ្ឋកិច្ច ចំនួន២ម៉ោងក្នុង១សប្តាហ៍ លើមុខជំនាញគណនេយ្យនិងគ្រប់គ្រង ដែលមានចំនួន ៧៦ម៉ោងក្នុងមួយឆ្នាំ។*

## ៧- គោលការណ៍នៃការបង្រៀន

**៧.១- គោលការណ៍ទី១**

ការបង្រៀនគឺជាសកម្មភាពសម្របសម្រួលការរៀនរបស់សិស្សដើម្បីឱ្យពួកគេមានវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទាដោយប្រើប្រាស់វិធីសាស្ត្រគោលវិធីសិស្សមជ្ឈមណ្ឌល។

**៧.២- គោលការណ៍ទី២**

ការបង្រៀនគឺជាសកម្មភាពជួយនិងលើកទឹកចិត្តសិស្សឱ្យចេះរបៀបរៀនដោយខ្លួនឯងយ៉ាងសកម្ម មានប្រសិទ្ធភាពនិងទទួលខុសត្រូវ ដើម្បីស្វែងយល់ ឆ្លើរិចារ និងអនុវត្តចំណេះដឹង សម្រាប់ការសិក្សានិងការរស់នៅប្រចាំថ្ងៃដោយប្រើប្រាស់វិធីសាស្ត្រទំនើបដូចជាសហការ អង្កេត។ល។

**៧.៣- គោលការណ៍ទី៣**

ការបង្រៀនត្រូវបន្តពង្រឹងនិងពង្រីកចំណេះដឹង បទពិសោធ ទេពកោសល្យ និងចំណង់ចំណូលចិត្តរបស់សិស្ស ដើម្បីឱ្យពួកគេស្រឡាញ់និងផ្តល់តម្លៃដល់ការសិក្សា។

**៧.៤- គោលការណ៍ទី៤**

ការបង្រៀនត្រូវតែផ្សារភ្ជាប់ទៅនឹងបរិស្ថានជុំវិញ តាមរយៈការប្រើប្រាស់វិធីវិទ្យាសាស្ត្រនិងសម្ភារៈឧបទេសរួមទាំងបច្ចេកវិទ្យាព័ត៌មាននិងទូរគមនាគមន៍សម្បូរបែបនិងមានបច្ចុប្បន្នភាព។

## ៨- វាយតម្លៃការរៀននិងបង្រៀន

ការវាយតម្លៃលទ្ធផលសិក្សារបស់សិស្សត្រូវធ្វើឡើងចំពោះវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា។ ការវាយតម្លៃជាដំណើរការជានិរន្តរ៍សម្រាប់ប្រមូលវិភាគនិងឆ្លុះបញ្ចាំងភស្តុតាងអំពីកម្រិតនៃសមត្ថភាពរបស់សិស្សក្រោយពីដំណើរការរៀននិងបង្រៀនទាំងក្នុងថ្នាក់ទាំងក្រៅថ្នាក់។ ការវាយតម្លៃគឺសំដៅរកព័ត៌មានឬភស្តុតាង ដើម្បីសន្និដ្ឋានសម្រេចចិត្តកែវិធីនិងផ្តល់ធាតុចូលជួយដល់ការកែលម្អដំណើរការរៀនរបស់សិស្សនិងដំណើរការបង្រៀនរបស់គ្រូឱ្យឆ្លើយតបនឹងស្តង់ដាលទ្ធផលសិក្សារំពឹងទុកក្នុងកម្មវិធីសិក្សាជាតិ។

**៨.១- គោលការណ៍ទី១ : វាយតម្លៃសមត្ថភាពរបស់សិស្សនិងគ្រូបង្រៀន**

- វិជ្ជាសម្បទា
- បំណិនសម្បទា
- ចរិយាសម្បទា
- ការអនុវត្តសមត្ថភាព

**៨.២- គោលការណ៍ទី២ : វាយតម្លៃពីប្រសិទ្ធភាពនិងប្រសិទ្ធផលរបស់ប្រព័ន្ធអប់រំ**

- ធនធាន(មនុស្សនិងសម្ភារៈ)
- ការគ្រប់គ្រងនិងការដឹកនាំ

**៨.៣- គោលការណ៍ទី៣ : ស្ថាប័នមានសមត្ថកិច្ចវាយតម្លៃអប់រំ**

- នាយកដ្ឋានធានាគុណភាពអប់រំ
- នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា

- សាលារៀន(នាយក គ្រូ សិស្ស អាណាព្យាបាលសិស្ស ...)
- ស្ថាប័នពាក់ព័ន្ធផ្សេងៗ

**៨.៤- គោលការណ៍ទី៤ : ក្របខណ្ឌវាយតម្លៃអប់រំ**

**៨.៤.១- ថ្នាក់តំបន់និងអន្តរជាតិ**

ការវាយតម្លៃថ្នាក់តំបន់និងអន្តរជាតិធ្វើឡើង ដើម្បីវាស់សមត្ថភាពសិស្សកម្ពុជាជាមួយនឹងសមត្ថភាពសិស្សនៃបណ្ដាប្រទេសនានាលើមុខវិជ្ជាកម្រិតថ្នាក់និងសិស្សមួយចំនួនតែប៉ុណ្ណោះក្នុងគោលដៅស្វែងរកចំណុចខ្លាំងនិងចំណុចខ្សោយដើម្បីកែលម្អគុណភាពអប់រំនៅកម្ពុជា។

**៨.៤.២- ថ្នាក់ជាតិ**

ការវាយតម្លៃថ្នាក់ជាតិធ្វើឡើងដើម្បីវាស់សមត្ថភាពសិស្សតាមកម្រិតថ្នាក់ឬតាមកម្រិតភូមិសិក្សា។ ការវាយតម្លៃថ្នាក់ជាតិ គឺអនុវត្តចំពោះសិស្សមួយចំនួនតែប៉ុណ្ណោះ។ ការវាយតម្លៃថ្នាក់ជាតិត្រូវធ្វើឡើង ចំពោះមុខវិជ្ជាគោលមួយចំនួនតែប៉ុណ្ណោះ ដូចជាភាសាខ្មែរ គណិតវិទ្យា សីលធម៌ពលរដ្ឋវិជ្ជានិងវិទ្យាសាស្ត្រធម្មជាតិ។

**៨.៤.៣- ថ្នាក់សាលារៀននិងកម្រិតថ្នាក់**

ការវាយតម្លៃកម្រិតសាលារៀននិងកម្រិតថ្នាក់ត្រូវធ្វើឡើងនៅតាមសាលារៀននីមួយៗក្នុងគោលបំណងវាយតម្លៃលទ្ធផលនៃការអនុវត្តកម្មវិធីសិក្សានៅក្នុងសាលារៀនទាំងនោះ។ ការវាយតម្លៃកម្រិតសាលារៀននិងកម្រិតថ្នាក់នឹងត្រូវធ្វើឡើងដោយគណៈគ្រប់គ្រងសាលារៀននិងគ្រូបង្រៀនសម្រាប់បង្កើនគុណភាពនិងប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីសិក្សា។

**៨.៤.៤- ថ្នាក់រៀន**

ការវាយតម្លៃនេះត្រូវធ្វើឡើងដោយគ្រូបង្រៀនតាមថ្នាក់និងមុខវិជ្ជានីមួយៗក្នុងគោលបំណងវាយ តម្លៃលទ្ធផលនៃការសិក្សារបស់សិស្សម្នាក់ៗដោយផ្ដោតទៅលើចំណេះដឹង បំណិន និងឥរិយាបថទៅតាម មេរៀននីមួយៗ។ វិធីសាស្ត្រនៃការវាយតម្លៃមានដូចជាការសួរសំណួរនិងធ្វើលំហាត់ ការពិភាក្សា ការសង្កេត កិច្ចការផ្ទះ ការប្រឡង និងគម្រោងស្រាវជ្រាវ។ល។ ដើម្បីវាយតម្លៃលទ្ធផលសិក្សាក្នុងថ្នាក់រៀននីមួយៗ គ្រូបង្រៀនត្រូវប្រមូល វិភាគ សំយោគ និងបកស្រាយលទ្ធផលនៃការវាយតម្លៃដើម្បីសម្រេចជ្រើសរើស និងកែសម្រួលវិធីសាស្ត្ររៀននិងបង្រៀន។ លទ្ធផលនៃការវាយតម្លៃនេះ ក៏នឹងត្រូវប្រើប្រាស់ក្នុងការវាយតម្លៃសាលារៀនផងដែរ។

**៨.៥- គោលការណ៍ទី៥ : ការប្រើប្រាស់លទ្ធផលនៃការវាយតម្លៃ**

លទ្ធផលនៃការវាយតម្លៃនឹងត្រូវប្រើប្រាស់ដោយស្ថាប័នពាក់ព័ន្ធផ្សេងៗគ្នាសម្រាប់កំណែទម្រង់និងកែលម្អប្រសិទ្ធភាព គណនេយ្យភាព និងគោលនយោបាយអប់រំនៃការអនុវត្តកម្មវិធីសិក្សានៅកម្រិតថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងសាលារៀនក្នុងគោលបំណងលើកកម្ពស់គុណភាពអប់រំជាតិ។ លទ្ធផលនឹងត្រូវបានប្រើប្រាស់សម្រាប់៖

- លើកទឹកចិត្តឱ្យសិស្សប្រឹងរៀនបន្ត ដោយកែលម្អចំណុចខ្សោយទាក់ទងនឹងឥរិយាបថ ទម្លាប់ វិធី និងសកម្មភាពរៀនរបស់សិស្ស
- ប្រមូលព័ត៌មានមូលដ្ឋាននិងភស្តុតាងឱ្យគ្រូយកទៅវាស់ស្ទង់ប្រសិទ្ធភាពនៃការបង្រៀន និង កែលម្អឥរិយាបថ ទម្លាប់ វិធី និងសកម្មភាពបង្រៀនបន្តក្នុងពេលខាងមុខក្នុងការគ្រប់គ្រងនិងការអនុវត្ត ដើម្បីកែលម្អគោលនយោបាយអប់រំ
- ប្រមូលព័ត៌មានដែលអាចចែករំលែកដល់មាតាបិតា និងអាណាព្យាបាល និយោជក និង សាធារណៈអំពីការសម្រេចលទ្ធផលសិក្សារបស់សិស្ស ព័ត៌មានអំពីប្រសិទ្ធភាពនៃការគ្រប់គ្រងរបស់ប្រព័ន្ធអប់រំទាំងមូល និងតាមកម្រិតនីមួយៗ។

## ៩- ការអភិវឌ្ឍសមត្ថភាពគ្រូបង្រៀន

ដើម្បីសម្រេចបាននូវការអនុវត្តក្របខណ្ឌកម្មវិធីសិក្សានេះការអភិវឌ្ឍសមត្ថភាពគ្រូបង្រៀនត្រូវផ្តោតលើចំណុចសំខាន់ៗដូចខាងក្រោម៖

៩.១- ពង្រឹងសមត្ថភាពគ្រូបង្រៀនឱ្យមានចំណេះដឹងច្បាស់លាស់និងស៊ីជម្រៅទៅលើកម្មវិធីសិក្សាមុខវិជ្ជាបង្រៀន និងវិធីសាស្ត្របង្រៀន។

៩.២- ពង្រឹងសមត្ថភាពគ្រូបង្រៀនឱ្យមានបំណិនក្នុងការវាយតម្លៃ លើលទ្ធផលសិក្សារបស់សិស្សតាមកម្រិតថ្នាក់និងសាលារៀននិងប្រើប្រាស់លទ្ធផល ដើម្បីកែលម្អវិធីសាស្ត្ររៀននិងបង្រៀនទៅតាមតម្រូវការពិសេសរបស់សិស្ស។

៩.៣- គាំទ្រគ្រូបង្រៀនទាំងផ្នែកបច្ចេកទេសសម្ភារៈឧបទេសនិងស្មារតី ដើម្បីលើកទឹកចិត្តពួកគាត់ឱ្យអនុវត្តវិធីសាស្ត្របង្រៀនផ្អែកលើគោលវិធីសិស្សមជ្ឈមណ្ឌលដើម្បីឆ្លើយតបទៅនឹងក្របខណ្ឌកម្មវិធីសិក្សានិងបរិបទពិភពលោក។

៩.៤- បណ្តុះបណ្តាលគ្រូបង្រៀនឱ្យមានសមត្ថភាពការច្នៃប្រឌិត និងការបង្កើតស្នាដៃក្នុងការសិក្សាស្រាវជ្រាវប្រតិបត្តិសម្រាប់ប្រើប្រាស់ក្នុងការរៀននិងបង្រៀនពេញមួយជីវិត និងមានលក្ខណៈជាប្រព័ន្ធច្បាស់លាស់។

## ១០- ការអនុវត្តក្របខណ្ឌកម្មវិធីសិក្សា

១០.១- សាលាគរុកោសល្យនិងវិក្រឹត្យការ មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ និងវិទ្យាស្ថានជាតិអប់រំ ត្រូវដាក់បញ្ចូលក្របខណ្ឌកម្មវិធីសិក្សា ស្តង់ដាកម្មវិធីសិក្សា និងកម្មវិធីសិក្សាលម្អិតក្នុងការបណ្តុះបណ្តាល។

១០.២- បំប៉នក្របខណ្ឌកម្មវិធីសិក្សា ស្តង់ដាកម្មវិធីសិក្សា និងកម្មវិធីសិក្សាលម្អិតដល់គ្រូបង្គោលមន្ទីរអប់រំ គ្រូបង្គោលអប់រំស្រុក/ខណ្ឌ គណៈគ្រប់គ្រងសាលារៀន និងគ្រូបង្រៀន។

## ឯកសារពិគ្រោះ


ក្រសួងអប់រំ(១៩៨០ក)កម្មវិធីបឋមសិក្សាវិជ្ជាទូទៅ ហូជីមិញ បោះពុម្ពនៅទីក្រុងហូជីមិញតាមកម្មវិធីសហប្រតិបត្តិការរវាងក្រសួងអប់រំសាធារណរដ្ឋប្រជាមានិតកម្ពុជា និងក្រសួងអប់រំសាធារណរដ្ឋសង្គមនិយមវៀតណាម ក្រសួងអប់រំសាធារណរដ្ឋប្រជាមានិតកម្ពុជា។

ក្រសួងអប់រំ(១៩៨០ខ) កម្មវិធីសម្រាប់កម្រិតសិក្សាទី២និងកម្រិតសិក្សាទី២ ទីស្តីការរដ្ឋមន្ត្រីក្រសួងអប់រំមជ្ឈមណ្ឌលនិពន្ធកម្មវិធីនិងសៀវភៅសិក្សា សាធារណរដ្ឋប្រជាមានិតកម្ពុជា។

ក្រសួងអប់រំ(១៩៨៧) កម្មវិធីបឋមសិក្សាចំណេះទូទៅ ភ្នំពេញ នៅរោងពុម្ពកាសែតភ្នំពេញ គ្រឹះស្ថានបោះពុម្ពផ្សាយអប់រំនៃរដ្ឋកម្ពុជានៅរោងពុម្ពកាសែតភ្នំពេញ។

ក្រសួងអប់រំ យុវជន និងកីឡា(១៩៩៦ក) កម្មវិធីសិក្សាគោលសម្រាប់មធ្យមសិក្សាទុតិយភូមិ ភ្នំពេញ វិទ្យាស្ថានស្រាវជ្រាវនៃក្រសួងអប់រំ យុវជន និងកីឡានៃព្រះរាជាណាចក្រកម្ពុជា។

ក្រសួងអប់រំ យុវជន និងកីឡា(១៩៩៦ខ) កម្មវិធីសិក្សាគោលសម្រាប់មធ្យមសិក្សាបឋមភូមិ ភ្នំពេញ វិទ្យាស្ថានស្រាវជ្រាវនៃក្រសួងអប់រំ យុវជន និងកីឡានៃព្រះរាជាណាចក្រកម្ពុជា។

ក្រសួងអប់រំ យុវជន និងកីឡា(១៩៩៦គ)កម្មវិធីសិក្សាគោលសម្រាប់បឋមសិក្សា ភ្នំពេញ វិទ្យាស្ថានស្រាវជ្រាវនៃក្រសួងអប់រំ យុវជន និងកីឡានៃព្រះរាជាណាចក្រកម្ពុជា។

ក្រសួងអប់រំ យុវជន និងកីឡា(២០០០) គោលនយោបាយស្តីពីការអប់រំកុមារតូច ភ្នំពេញ ក្រសួងអប់រំ យុវជន និងកីឡានៃព្រះរាជាណាចក្រកម្ពុជា។

ក្រសួងអប់រំ យុវជន និងកីឡា(២០០៤) គោលនយោបាយសម្រាប់អភិវឌ្ឍន៍កម្មវិធីសិក្សាចំណេះទូទៅ ២០០៥-២០០៩ ភ្នំពេញ នាយកដ្ឋានស្រាវជ្រាវគរុកោសល្យនៃក្រសួងអប់រំ យុវជន និងកីឡានៃព្រះរាជាណាចក្រកម្ពុជា។

ក្រសួងអប់រំ យុវជន និងកីឡា(២០០៦ក) កម្មវិធីសិក្សាគោលសម្រាប់អប់រំមូលដ្ឋានចំណេះទូទៅ ភ្នំពេញ ក្រសួងអប់រំ យុវជន និងកីឡានៃព្រះរាជាណាចក្រកម្ពុជា។

ក្រសួងអប់រំ យុវជន និងកីឡា(២០០៦ខ) កម្មវិធីសិក្សាលំអិតគណិតវិទ្យាសម្រាប់អប់រំមូលដ្ឋានចំណេះទូទៅ ភ្នំពេញ នាយកដ្ឋានស្រាវជ្រាវគរុកោសល្យនៃក្រសួងអប់រំ យុវជន និងកីឡានៃព្រះរាជាណាចក្រកម្ពុជា។

ក្រសួងអប់រំ យុវជន និងកីឡា(២០០៦គ) កម្មវិធីសិក្សាលំអិតភាសាខ្មែរសម្រាប់អប់រំមូលដ្ឋានចំណេះទូទៅ ភ្នំពេញ នាយកដ្ឋានស្រាវជ្រាវគរុកោសល្យនៃក្រសួងអប់រំ យុវជន និងកីឡានៃព្រះរាជាណាចក្រកម្ពុជា។

ក្រសួងអប់រំ យុវជន និងកីឡា(២០០៦ឃ) កម្មវិធីសិក្សាលំអិតវិទ្យាសាស្ត្រសម្រាប់អប់រំមូលដ្ឋានចំណេះទូទៅ ភ្នំពេញ នាយកដ្ឋានស្រាវជ្រាវគរុកោសល្យនៃក្រសួងអប់រំ យុវជន និងកីឡានៃព្រះរាជាណាចក្រកម្ពុជា។

ក្រសួងអប់រំ យុវជន និងកីឡា(២០០៦ង) កម្មវិធីសិក្សាលំអិតសិក្សាសង្គម សម្រាប់អប់រំមូលដ្ឋានចំណេះទូទៅ ភ្នំពេញ នាយកដ្ឋានស្រាវជ្រាវគរុកោសល្យនៃក្រសួងអប់រំ យុវជន និងកីឡានៃព្រះរាជាណាចក្រកម្ពុជា។

ក្រសួងអប់រំ យុវជន និងកីឡា(២០០៦ច)កម្មវិធីសិក្សាវិទ្យាសាស្ត្រសម្រាប់មធ្យមសិក្សាទុតិយភូមិ ភ្នំពេញ នាយកដ្ឋានស្រាវជ្រាវគរុកោសល្យនៃក្រសួងអប់រំ យុវជន និងកីឡានៃព្រះរាជាណាចក្រកម្ពុជា។

ក្រសួងអប់រំ យុវជន និងកីឡា(២០០៦ឆ) គោលនយោបាយអប់រំបំណិនជីវិត ភ្នំពេញ នាយកដ្ឋានស្រាវជ្រាវគរុកោសល្យនៃក្រសួងអប់រំ យុវជន និងកីឡានៃព្រះរាជាណាចក្រកម្ពុជា។

ក្រសួងអប់រំ យុវជន និងកីឡា(២០០៩) កម្មវិធីសិក្សាលម្អិតភាសាខ្មែរនិងអក្សរសាស្ត្រខ្មែរ ផែនដីនិងបរិស្ថានវិទ្យា និងសិក្សាសង្គម សម្រាប់មធ្យមសិក្សាទុតិយភូមិថ្នាក់ទី១០ ទី១១ និងទី១២ ភ្នំពេញ នាយកដ្ឋានស្រាវជ្រាវគរុកោសល្យនៃក្រសួងអប់រំ យុវជន និងកីឡានៃព្រះរាជាណាចក្រកម្ពុជា។

ក្រសួងអប់រំ យុវជន និងកីឡា(២០១០) ផែនការគោលបច្ចេកវិទ្យាព័ត៌មាននិងសារគមនាគមន៍ក្នុងវិស័យអប់រំ ២០០៩-២០១៣ ភ្នំពេញ ក្រសួងអប់រំ យុវជន និងកីឡានៃព្រះរាជាណាចក្រកម្ពុជា។

ក្រសួងអប់រំ យុវជន និងកីឡា(២០១៤ក) គោលនយោបាយស្តីពីចក្ខុវិស័យឧត្តមសិក្សា២០៣០ ភ្នំពេញ ក្រសួងអប់រំ យុវជន និងកីឡានៃព្រះរាជាណាចក្រកម្ពុជា។

ក្រសួងអប់រំ យុវជន និងកីឡា(២០១៤ខ) គោលនយោបាយស្តីពីការអប់រំបច្ចេកទេស ភ្នំពេញ ក្រសួងអប់រំ យុវជន និងកីឡានៃព្រះរាជាណាចក្រកម្ពុជា។

ក្រសួងអប់រំ យុវជន និងកីឡា(២០១៤គ) គោលនយោបាយស្តីពីធនធានមនុស្សក្នុងវិស័យអប់រំ ភ្នំពេញ ក្រសួងអប់រំ យុវជន និងកីឡានៃព្រះរាជាណាចក្រកម្ពុជា។

ក្រសួងអប់រំ យុវជន និងកីឡា(២០១៤ឃ) គោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជា ភ្នំពេញ ក្រសួងអប់រំ យុវជន និងកីឡានៃព្រះរាជាណាចក្រកម្ពុជា។

ក្រសួងអប់រំ យុវជន និងកីឡា(២០១៤ង) គោលនយោបាយស្តីពីកម្មវិធីសមមូលអប់រំក្រៅប្រព័ន្ធ ភ្នំពេញ ក្រសួងអប់រំ យុវជន និងកីឡានៃព្រះរាជាណាចក្រកម្ពុជា។

ក្រសួងអប់រំ យុវជន និងកីឡា(២០១៤ច) គោលនយោបាយស្តីពីសៀវភៅសិក្សានិងមគ្គុទ្ទេសក៍សម្រាប់ការអភិវឌ្ឍសៀវភៅសិក្សាគោល ភ្នំពេញ ក្រសួងអប់រំ យុវជន និងកីឡានៃព្រះរាជាណាចក្រកម្ពុជា។

ក្រសួងអប់រំ យុវជន និងកីឡា(២០១៤ឆ) គោលនយោបាយស្តីពីការអភិវឌ្ឍការស្រាវជ្រាវក្នុងវិស័យអប់រំ ភ្នំពេញ ក្រសួងអប់រំ យុវជន និងកីឡានៃព្រះរាជាណាចក្រកម្ពុជា។

ក្រសួងអប់រំ យុវជន និងកីឡា(២០១៤ជ) គោលការណ៍ណែនាំស្តីពីការត្រួតពិនិត្យគុណភាពនៃការសាងសង់អគារសិក្សា ភ្នំពេញ ក្រសួងអប់រំ យុវជន និងកីឡានៃព្រះរាជាណាចក្រកម្ពុជា។

ក្រសួងអប់រំ យុវជន និងកីឡា(២០១៤ឈ) គោលនយោបាយស្តីពីសាលាមធ្យមសិក្សាធនធាន ភ្នំពេញ នាយកដ្ឋានស្រាវជ្រាវគរុកោសល្យនៃក្រសួងអប់រំ យុវជន និងកីឡានៃព្រះរាជាណាចក្រកម្ពុជា។

ក្រសួងអប់រំ យុវជន និងកីឡា(២០១៤ញ) គោលនយោបាយថ្នាក់ជាតិសម្រាប់ការងារអប់រំក្រៅប្រព័ន្ធ ២០០៤-២០១៥ ភ្នំពេញ ក្រសួងអប់រំ យុវជន និងកីឡានៃព្រះរាជាណាចក្រកម្ពុជា។

ក្រសួងអប់រំ យុវជន និងកីឡា(២០១៤ដ) គោលនយោបាយស្តីពីគ្រូបង្រៀន ភ្នំពេញ ក្រសួងអប់រំ យុវជន និងកីឡានៃព្រះរាជាណាចក្រកម្ពុជា។

ក្រសួងអប់រំ យុវជន និងកីឡា(២០១៤ឋ) ផែនការគោលនៃប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ ២០១៤-១០១៨

ភ្នំពេញ នាយកដ្ឋានស្រាវជ្រាវគរុកោសល្យនៃក្រសួងអប់រំ យុវជន និងកីឡានៃព្រះរាជាណាចក្រកម្ពុជា។

ក្រសួងអប់រំ យុវជន និងកីឡា(២០១៤ឱ)ផែនការគោលសម្រាប់អភិវឌ្ឍការស្រាវជ្រាវក្នុងការអប់រំ ២០១១-២០១៥ ភ្នំពេញ ក្រសួងអប់រំ យុវជន និងកីឡានៃព្រះរាជាណាចក្រកម្ពុជា។

ក្រសួងអប់រំ យុវជន និងកីឡា(២០១៤ឍ) ផែនការគោលបច្ចេកវិទ្យាព័ត៌មាននិងសារគមនាគមន៍ក្នុងវិស័យអប់រំ ភ្នំពេញ ក្រសួងអប់រំ យុវជន និងកីឡានៃព្រះរាជាណាចក្រកម្ពុជា។

ក្រសួងអប់រំ យុវជន និងកីឡា(២០១៤ណ) ផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ ២០១៤ - ២០១៨ ភ្នំពេញ ក្រសួងអប់រំ យុវជន និងកីឡានៃព្រះរាជាណាចក្រកម្ពុជា។

ក្រសួងអប់រំ យុវជន និង កីឡា(២០១៤ត) ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០០៩-២០១៣ ភ្នំពេញ ក្រសួងអប់រំ យុវជន និងកីឡានៃព្រះរាជាណាចក្រកម្ពុជា។

ក្រសួងអប់រំ យុវជន និងកីឡា(២០១៤ថ) ផែនការសកម្មភាពជាតិស្តីពីការគាំពារនិងអភិវឌ្ឍកុមារតូច ២០១៤-២០១៨ ភ្នំពេញ ក្រសួងអប់រំ យុវជន និងកីឡានៃព្រះរាជាណាចក្រកម្ពុជា។

NEP(2014) សិទ្ធិទទួលបានការអប់រំនៅប្រទេសកម្ពុជាការសិក្សានៅកម្រិតមូលដ្ឋាន ភាពជាដៃគូនៃអង្គការក្រៅរដ្ឋាភិបាល(NGO Education Partnership-NEP) សេចក្តីសម្រេចស្តីពីការអនុវត្តកម្មវិធីសិក្សាតាមប្រព័ន្ធក្រេឌីតនិងការផ្ទេរក្រេឌីត(២០០៤)។

Chet, C., Ngin , C., Chhinh, S., Dy S. S. & David, F. (2015). Reviews of educational contents, pedagogies and connectivity of curriculum and its relevance to economic development in Cambodia: A focus on Khmer, mathematics, and science for grades 9 and 12.

Un, L. et al. (2014). Upper secondary school curriculum reform in Cambodia: Relevance for employment and tertiary education.

ASEAN (2012). ASEAN curriculum sourcebook.

Ministry of Education of Thailand (2008). Basic education core curriculum.

Ministry of Education of Malaysia (2013). Malaysian education blueprint 2013-2025.

Ministry of Education of Singapore (2013). Science syllabus.

Ministry of Education of Singapore (2006). Mathematics syllabus.

Ministry of Education of Singapore (2008). Arts syllabus.

Ministry of Education of Singapore (2014). Character and citizen education syllabus.

Ministry of Education of Singapore (2012). Singapore’s education system.

Ministry of Education of Singapore (2012). Nurturing early learners: Curriculum framework for kindergarten in Singapore.

**ឧបសម្ព័ន្ធ១៖ សទ្ទានុក្រម**

| ល.រ. | វាក្យសព្ទ | ប្រភេទពាក្យ | អង់គ្លេស | សេចក្ដីពន្យល់ |
|---|---|---|---|---|
| ១ | ការអប់រំ | ន | Education | ដំណើរការស្វែងយល់ ដើម្បីភាពរីក ចម្រើននៃបុគ្គលម្នាក់ៗនិងសង្គមដោយការផ្ទេរចំណេះដឹង ការហ្វឹកហាត់ ការបណ្តុះបណ្តាល ការសាបព្រោះនូវវប្បធម៌ ភាពច្នៃប្រឌិត ភាពជឿនលឿនខាងផ្នែកបញ្ញា ភាពច្នៃប្រឌិតផ្នែកចំណេះដឹង ដែលកើតចេញពីបរិស្ថានជុំវិញសង្គមនៃការស្វែងយល់ និងកត្តាជំរុញឱ្យបុគ្គលអាចស្វែងយល់បានពេញមួយជីវិត។ |
| ២ | កម្មវិធីសិក្សា | | Curriculum | ក្របខណ្ឌអនុវត្តចំណេះដឹងនិងបទពិសោធដែល មានឡើងដើម្បីអភិវឌ្ឍដល់សិស្សានុសិស្សឱ្យមានចំណេះដឹង ជំនាញនិងលក្ខណៈសម្បត្តិដែលបានកំណត់ទុក។ កម្មវិធីសិក្សាប្រៀបដូចជាផែនទីកំណត់ទិសដៅនៃការអភិវឌ្ឍដល់សិស្សានុសិស្សឱ្យឈានដល់មាត្រដ្ឋាននៃការរៀនសូត្រដែលជាគោលដៅ និងមានការវាយតម្លៃការស្វែងយល់ ដើម្បីឱ្យជ្រួតជ្រាបពីការវិវឌ្ឍទៅមុខនៃសិស្សានុសិស្សម្នាក់ៗក្នុងការអភិវឌ្ឍដើម្បីឈានទៅដល់ស្តង់ដាដែលបានកំណត់ទុក។ |
| ៣ | គោលបំណង | ន | Goal | កម្មវត្ថុចម្បងដែលបានគ្រោងទុកក្នុងក្តីសង្ឃឹមថាធ្វើឱ្យសម្រេច។ |
| ៤ | គោលដៅ | ន | Target | កម្មវត្ថុចម្បងដែលបានដៅទុក ដើម្បីធ្វើឱ្យសម្រេច។ |
| ៥ | វិជ្ជាសម្បទា | ន | Knowledge | ចំណេះដឹងដែលសិស្សានុសិស្សទទួលបានពីកម្មវិធីអប់រំ ហើយអាចយកទៅអនុវត្តក្នុងជីវភាពប្រចាំថ្ងៃរបស់ខ្លួន។ |
| ៦ | បំណិនសម្បទា | ន | Skill | ភាពប៉ិនប្រសប់ដែលសិស្សានុសិស្សទទួលបានពីកម្មវិធីអប់រំ ហើយអាចយកទៅអនុវត្តក្នុងជីវភាពប្រចាំថ្ងៃរបស់ខ្លួនបាន។ |
| ៧ | ចរិយាសម្បទា | ន | Attitude | អត្តចរិត មនោសញ្ចេតនា ដែលសិស្សានុសិស្សត្រូវចេះប្រកាន់យកក្នុងស្ថានភាពជាក់ស្តែងមួយដើម្បីដាក់ចេញនូវវិធានការឬដំណោះស្រាយសមស្របនិងស្មើភាពជាមួយដៃគូ។ |
| ៨ | ការអប់រំចំណេះទូទៅ | ន | General Education | ការបណ្តុះបណ្តាលនូវចំណេះដឹងជាមូលដ្ឋាន ចាំបាច់សម្រាប់ការរស់នៅរបស់សិស្សានុសិស្ស។ |
| ៩ | ការអប់រំបច្ចេកទេស | ន | Technical Education | ការបណ្តុះចំណេះដឹងដែលជាវិធានគន្លឹះក្នុងការអនុវត្តការងារឬមុខរបរវិជ្ជាជីវៈ។ |
| ១០ | សម្ភារៈឧបទេស | ន | Teaching Materials | សម្ភារៈដែលជាជំនួយដល់ការបង្រៀនដើម្បីជួយដាស់ស្មារតីសិស្សានុសិស្សឱ្យកើតមានចំណាប់អារម្មណ៍ មានការយល់ដឹង ការស្វែងយល់ និងការជួយលើកស្ទួយឱ្យការរៀនសូត្រទៅមុខយ៉ាង |

| | | | | |
|---|---|---|---|---|
| | | | | រលូនប្រកបដោយមានប្រសិទ្ធភាព។ សម្ភារៈឧបទេស មានច្រើនសណ្ឋានដូចជាសារពត៌មាន សម្ភារៈបច្ចេកវិទ្យា សម្ភារៈធម្មជាតិ ការជ្រើសរើសឧបករណ៍ដែលប្រើការស្វែងយល់ និងអ្វីដែលសំខាន់គឺស្របតាមកម្មវត្ថុនៃការរៀនសូត្រ វិធីរៀនសូត្ររបស់សិស្សានុសិស្ស និងភាពខុសគ្នារវាងបុគ្គលម្នាក់ៗ។ |
| ១១ | ការវាយតម្លៃ | ន | Evaluation | ដំណើរការប្រមូលទិន្នន័យព័ត៌មាននិងភស្តុតាង ដែលបញ្ជាក់ឱ្យឃើញពីការអភិវឌ្ឍ ការរីវឌ្ឍទៅមុខ និងភាពជោគជ័យផ្នែកការរៀនសូត្ររបស់សិស្សានុសិស្សស្របតាមប្រព័ន្ធ ដើម្បីជាប្រយោជន៍ដល់ការលើកស្ទួយឱ្យសិស្សានុសិស្សមានការអភិវឌ្ឍនិងស្វែងយល់ប្រកបដោយសក្តានុពល។ |
| ១២ | អក្ខរពុទ្ធិ | ន | Litteracy knowledge | ចំណេះដឹងផ្នែកអក្សរសាស្ត្រ វេយ្យាករណ៍។ |
| ១៣ | លេខពុទ្ធិ | ន | Numeracy knowledge | ចំណេះដឹងផ្នែកលេខនព្វន្តនិងក្បួនគណនា។ |

## ឧបសម្ព័ន្ធ២ ៖ សមត្ថភាពរំពឹងទុកតាមភូមិសិក្សា

| សមត្ថភាព | មត្តេយ្យសិក្សា | បឋមសិក្សា | មធ្យមសិក្សា បឋមភូមិ | មធ្យមសិក្សា ទុតិយភូមិ | ការអប់រំបច្ចេកទេស |
|---|---|---|---|---|---|
| វិជ្ជាសម្បទា | ស្គាល់ អានព្យញ្ជនៈ ស្រៈ ព្យាង្គ ពាក្យ និងឃ្លា។ | មានចំណេះដឹងមូលដ្ឋានគ្រឹះរឹងមាំផ្នែកភាសាខ្មែរ សិក្សាសង្គម គណិតវិទ្យា និង អភិវឌ្ឍសុខភាពកាយសម្បទានិងសីលធម៌។ | មានចំណេះដឹងមូលដ្ឋានគ្រឹះ រឹងមាំផ្នែកភាសាខ្មែរ វិទ្យាសាស្ត្រសង្គម គណិតវិទ្យានិង អភិវឌ្ឍសុខភាពកាយសម្បទា និង សីលធម៌។ | មានចំណេះដឹងមូលដ្ឋានគ្រឹះរឹងមាំផ្នែកអក្សរសាស្ត្រខ្មែរ វិទ្យាសាស្ត្រសង្គម គណិតវិទ្យានិង អភិវឌ្ឍសុខភាពកាយសម្បទានិងសីលធម៌។ | ទទួលបានចំណេះដឹងមូលដ្ឋានវិទ្យាសាស្ត្រដែលទាក់ទងនឹងមុខវិជ្ជាជំនាញ។ |
| | រាប់ចំនួន លេខ គូសតាមលេខពីរខ្ទង់ ស្គាល់រូបរាងវត្ថុផ្សេងៗ ទំហំ និងរង្វាស់។ | មានចំណេះដឹងមូលដ្ឋានគ្រឹះផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍ (ICT) និង ភាសាបរទេស។ | មានចំណេះដឹងមូលដ្ឋានគ្រឹះផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍ (ICT) និង ភាសាបរទេស។ | មានចំណេះដឹងមូលដ្ឋានគ្រឹះរឹងមាំផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍ (ICT) និងភាសាបរទេស។ | បកស្រាយបញ្ញត្តិមូលដ្ឋានគ្រឹះនៃមុខជំនាញឯកទេសនីមួយៗ។ |
| បំណិន សម្បទា | ចេះប្រើភាសាខ្មែរសម្រាប់និយាយ ស្តាប់ និងទំនាក់ទំនង។ | មានបំណិនមូលដ្ឋានផ្នែកភាសាខ្មែរ (ការអាន ការសរសេរ ការនិយាយ និង ការស្តាប់)។ | មានបំណិនមូលដ្ឋានរឹងមាំ និងទូលំទូលាយផ្នែកភាសាខ្មែរ(ការអាន ការសរសេរ ការនិយាយ និង ការស្តាប់)។ | មានបំណិនមូលដ្ឋានរឹងមាំ ច្បាស់លាស់ និងទូលំទូលាយផ្នែកអក្សរសាស្ត្រខ្មែរ (ប្រៀបធៀប ពន្យល់ វិភាគ បកស្រាយ និងដោះស្រាយបញ្ហា)។ | អនុវត្តជំនាញឯកទេសដែលទទួលបានពីការបណ្តុះបណ្តាលប្រកបដោយប្រសិទ្ធភាព។ |
| | ចេះប្រើប្រាស់គណិតវិទ្យា (រាប់ គូសតាម និង ប្រៀបធៀប)។ | មានបំណិនមូលដ្ឋានផ្នែកគណិតវិទ្យា (គណនា ប្រៀបធៀបនិងដោះស្រាយ បញ្ហា)។ | មានបំណិនមូលដ្ឋានរឹងមាំផ្នែកគណិតវិទ្យា(គណនា ប្រៀបធៀប ពន្យល់ បកស្រាយ និងដោះស្រាយបញ្ហា)។ | មានបំណិនមូលដ្ឋានរឹងមាំនិងច្បាស់លាស់ផ្នែក គណិតវិទ្យា(គណនា ប្រៀបធៀប ពន្យល់ វិភាគ បកស្រាយ និងដោះស្រាយបញ្ហា)។ | ប្រតិបត្តិគ្រឿងម៉ាស៊ីននិង ឧបករណ៍ពាក់ព័ន្ធផ្សេងៗបាន។ |

| | | | | | |
|---|---|---|---|---|---|
| | ចេះអនាម័យខ្លួនប្រាណ។ | មានបំណិនប្រើប្រាស់ចំណេះដឹងវិទ្យាសាស្រ្តមូលដ្ឋាន។ | មានបំណិនប្រើប្រាស់ចំណេះដឹងវិទ្យាសាស្រ្តនិងបច្ចេកវិទ្យាព័ត៌មាននិងទូរគមនាគមន៍(ICT)មូលដ្ឋាន។ | មានបំណិនអនុវត្តចំណេះ ដឹងវិទ្យាសាស្រ្តនិងបច្ចេកវិទ្យាព័ត៌មាននិងទូរគមនាគមន៍(ICT)មូលដ្ឋាន។ | |
| | ចេះប្រើ ប្រាស់ចលករតូច (ចលនាម្រាមដៃ) និងចលករធំ (រាងកាយ)។ | មានបំណិនត្រិះរិះពិចារណា មូលដ្ឋានក្នុងការសិក្សា។ | មានបំណិនត្រិះរិះពិចារណា និងដោះស្រាយបញ្ហាមូលដ្ឋានក្នុងការសិក្សានិងក្នុងសង្គម។ | មានបំណិនត្រិះរិះពិចារណា និងដោះស្រាយបញ្ហារឹងមាំនិងទូលំទូលាយទាំងក្នុងការសិក្សាទាំងក្នុងសង្គម។ | |
| | ចេះផ្តល់ហេតុផលចំពោះទង្វើរបស់ខ្លួន។ | មានបំណិនប្រាស្រ័យទាក់ទងល្អក្នុងការសិក្សានិងក្នុងសង្គម។ | មានបំណិនប្រាស្រ័យទាក់ទងទូលំទូលាយសម្រាប់ការសិក្សានិងការរស់នៅប្រចាំថ្ងៃ | មានបំណិនប្រាស្រ័យទាក់ទងទូលំទូលាយនិងមានប្រសិទ្ធភាពក្នុងការសិក្សានិងក្នុងសង្គម។ | |
| | ចេះប្រើប្រាស់ពាក្យសម្តីនិងកាយវិការសមរម្យជាមួយមិត្តភក្តិ គ្រួសារ និងអ្នកដទៃ។ | មានបំណិនបង្ការនិងថែទាំសុខភាពបឋម។ | មានបំណិនបង្ការនិងថែទាំ សុខភាពបឋម។ | មានបំណិនបង្ការនិងថែទាំសុខភាពបឋម ។ | |
| | ស្គាល់ខុសស្គាល់ត្រូវ។ | មានសមត្ថភាពស្គាល់ខុសស្គាល់ត្រូវ។ | មានសមត្ថភាពស្គាល់ខុសស្គាល់ត្រូវ។ | មានសមត្ថភាពនិងសីលធម៌ក្នុងការការពារនិងការពង្រីកភាពត្រឹមត្រូវ។ | |
| **ចរិយាសម្បទា** | ចូលចិត្តការសិក្សាចេះឆ្ងល់ និងចង់ស្វែង យល់ពីអ្វីដែលថ្មីនិងប្លែក។ | ស្រឡាញ់និងផ្តល់តម្លៃដល់ការសិក្សាក្នុងសាលារៀន។ | ស្រឡាញ់និងផ្តល់តម្លៃដល់ការសិក្សាទាំងក្នុងប្រព័ន្ធទាំងក្រៅប្រព័ន្ធ។ | ស្រឡាញ់និងផ្តល់តម្លៃដល់ការសិក្សាពេញមួយជីវិត។ | មានស្មារតីទទួលខុសត្រូវនិងម្ចាស់ការលើការងាររបស់ខ្លួន។ |
| | ចេះជួយចែករំលែកនិងសហការគ្នា។ | ស្គាល់និងឱ្យតម្លៃសន្តានចិត្តមេត្តានិង | ស្គាល់និងឱ្យតម្លៃសន្តានចិត្តមេត្តានិង | ស្គាល់និងឱ្យតម្លៃសន្តានចិត្តមេត្តានិង | មានគំនិតច្នៃប្រឌិតថ្មីដើម្បីអាចដោះ |

| | | | | | |
|---|---|---|---|---|---|
| | | ករុណាចំពោះ គ្រួសារ មិត្តភក្តិ និង អ្នកដទៃ។ | ករុណាចំពោះ គ្រួសារ មិត្តភក្តិ និង អ្នកដទៃ។ | ករុណាចំពោះ គ្រួសារ មិត្តភក្តិ និង អ្នកដទៃ។ | ស្រាយបញ្ហាបាន។ |
| | ចូលចិត្តចម្រៀង របាំ និងតន្ត្រី ប្រពៃណីខ្មែរ។ | ស្គាល់ ស្រឡាញ់ ថែរក្សា និងការពារ វប្បធម៌ ប្រពៃណី ទំនៀមទម្លាប់ និង សិល្បៈជាតិ តំបន់ និងអន្តរជាតិ។ | ស្គាល់ ស្រឡាញ់ ថែរក្សា និងការពារ វប្បធម៌ ប្រពៃណី ទំនៀមទម្លាប់ និង សិល្បៈជាតិ តំបន់ និងអន្តរជាតិ។ | អភិរក្សនិងអភិវឌ្ឍ វប្បធម៌ ប្រពៃណី ទំនៀមទម្លាប់ និង សិល្បៈជាតិ តំបន់ និងអន្តរជាតិ។ | ស្រឡាញ់ការងារ ប្រតិបត្តិនិងធ្វើការ ជាក្រុមប្រកបដោយ ប្រសិទ្ធភាព។ |
| | ស្រឡាញ់បរិស្ថាន ស្អាត។ | ស្រឡាញ់និងឱ្យតម្លៃ បរិស្ថាន វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា។ | ស្រឡាញ់និងឱ្យ តម្លៃបរិស្ថាន វិទ្យាសាស្ត្រ និង បច្ចេកវិទ្យា។ | ស្រឡាញ់និងឱ្យ តម្លៃខ្ពស់ ដល់ បរិស្ថាន វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា។ | អភិវឌ្ឍបុគ្គលិក លក្ខណៈនិង មុខរបរ។ |
| | ស្រឡាញ់ខ្លួនឯង គ្រួសារ មិត្តភក្តិ គ្រូបង្រៀន និង អ្នកដទៃ។ | ស្រឡាញ់ភាព ស្អាតបាត ទាំងខ្លួន ប្រាណ សាលារៀន ផ្ទះសម្បែង និង ទីសាធារណៈ។ | ស្រឡាញ់ភាព ស្អាតបាត ទាំងខ្លួន ប្រាណ សាលារៀន ផ្ទះសម្បែង និង ទីសាធារណៈ។ | ស្រឡាញ់ភាព ស្អាតបាត ទាំងខ្លួន ប្រាណ សាលារៀន ផ្ទះសម្បែង និង ទីសាធារណៈ។ | មានស្មារតីអភិវឌ្ឍ សង្គមជាតិប្រកប ដោយចីរភាព។ |
| | | មានទម្លាប់និង អនុវត្តការរស់នៅ ប្រកបដោយ សុខ ភាពតាមរយៈ ការធ្វើពលកម្ម និង ហាត់កីឡា។ | មានទម្លាប់និង អនុវត្តការរស់នៅ ប្រកបដោយ សុខភាពតាមរយៈ ការធ្វើពលកម្ម និង ហាត់កីឡា។ | មានទម្លាប់និង អនុវត្តការរស់នៅ ប្រកបដោយសុខ ភាព តាមរយៈ ការធ្វើពលកម្ម និង ហាត់កីឡា។ | |
| | | ទទួលខុសត្រូវចំពោះ ទង្វើ ខ្លួនឯងក្នុងការ សិក្សានិងការរស់នៅ ប្រចាំថ្ងៃ។ | ទទួលខុសត្រូវ ចំពោះទង្វើ របស់ ខ្លួនឯងនិងរបស់ ក្រុម ទាំងក្នុងការ សិក្សា ទាំងក្នុងការ រស់នៅប្រចាំថ្ងៃ។ | ទទួលខុសត្រូវ ចំពោះទង្វើ របស់ ខ្លួនឯងនិងរបស់ ក្រុម ទាំងក្នុងការ សិក្សា ទាំងក្នុងការ រស់នៅប្រចាំថ្ងៃ។ | |

## ឧបសម្ព័ន្ធ៣ ៖ សីមាអភិវឌ្ឍពលរដ្ឋពេញលេញ

